ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន

# 2010-2019

បានទទួលការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា

នៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១០

# មាតិកា


**អារម្ភកថា** ........ ii
**អក្សរកាត់** ........ iii
**សេចក្តីសង្ខេប** ........ vi
**សេចក្តីផ្តើម** ........ 1
**ជំពូកទី ១** ........ 3
**ស្ថានភាពមីន/ស.ផ.ស. បច្ចុប្បន្ននៅកម្ពុជា** ........ 3
**ជំពូកទី ២** ........ 4
**ក្របខ័ណ្ឌយុទ្ធសាស្ត្រ** ........ 4
២.១. ទស្សនវិស័យ ........ 4
២.២. បេសកកម្ម ........ 5
២.៣. គោលដៅ ........ 5
គោលដៅទី១: កាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស. និងផលប៉ះពាល់អវិជ្ជមានដទៃទៀតដោយ៖ ........ 5
គោលដៅទី២: រួមចំណែកដល់ការជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រដោយ៖ ........ 5
គោលដៅទី៣: ធានានូវនិរន្តរភាពសមត្ថភាពជាតិក្នុងការដោះស្រាយបញ្ហាមីន/ស.ផ.ស. នៅសេសសល់ដោយ៖ ........ 5
គោលដៅទី៤: លើកកម្ពស់ស្ថិរភាព និងការរំសាយសព្វាវុធនៅក្នុងតំបន់ និងលើឆាកអន្តរជាតិដោយ៖ ........ 5
២.៤. ស្ថាប័ន និង ការសម្របសម្រួល ........ 5
២.៥. វិធានការអនុវត្ត ........ 7
២.៥.១. ការស្រាវជ្រាវទិន្នន័យមូលដ្ឋាន ........ 7
២.៥.២. ការរំដោះផ្ទៃដីសង្ស័យមានមីន/ស.ផ.ស. ........ 7
២.៥.៣. ការធ្វើផែនការ និងការចាត់អាទិភាព ........ 7
២.៥.៤. ការអភិវឌ្ឍសមត្ថភាព និងការសម្របសម្រួល ........ 8
២.៥.៥. ស្ថិរភាពក្នុងតំបន់ និងអន្តរជាតិ ........ 8
២.៥.៦. ការអប់រំកាត់បន្ថយគ្រោះថ្នាក់ និងកិច្ចជួយសង្គ្រោះជនរងគ្រោះ ........ 8
២.៥.៧. និរន្តរភាពសមត្ថភាព ........ 8
**ជំពូកទី ៣** ........ 9
**តម្រូវការធនធាន** ........ 9
**ជំពូកទី ៤** ........ 11
**ការតាមដានត្រួតពិនិត្យ និង វាយតម្លៃ** ........ 11
**សេចក្តីសន្និដ្ឋាន** ........ 12
**ឧបសម្ព័ន្ធ ក : តារាងសូចនាករ និងចំណុចដៅ** ........ 13
**ឧបសម្ព័ន្ធ ខ : តារាងវិភាជន៍ថវិកាពីឆ្នាំ ២០១០-២០១៩** ........ 19

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# អារម្ភកថា

គោលដៅចម្បងនៃការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលកម្ពុជា គឺការកាត់បន្ថយភាពក្រីក្រ។ សង្គ្រាមពីអតីតកាលបានបន្សល់ទុកនូវតំបន់ ដែលនៅមានការគំរាមដោយសារមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមជាច្រើនដែលបានធ្វើឲ្យមនុស្សស្លាប់ និងរបួសពិការ និងជាឧបសគ្គដល់ជីវភាពរស់នៅរបស់ប្រជាជនយើង ព្រមទាំងបានធ្វើឲ្យរាំងស្ទះដល់ការអភិវឌ្ឍប្រទេសជាតិទៀតផង។ រហូតមកដល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជារួមជាមួយនឹងដៃគូអភិវឌ្ឍបានប្រឹងប្រែងឆ្លើយតបយ៉ាងសកម្ម នូវតម្រូវការផ្នែកមនុស្សធម៌ និងការអភិវឌ្ឍដោយធ្វើការបោសសម្អាតផ្ទៃដីមានមីនបានជាច្រើនម៉ឺនហិកតាជូនដល់សហគមន៍មូលដ្ឋាន។ ក៏ប៉ុន្តែផលប៉ះពាល់ជាអវិជ្ជមានរបស់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ចំពោះការកាត់បន្ថយភាពក្រីក្រនៅកម្ពុជានៅតែជាបញ្ហាចម្បងនៅឡើយ ដែលនាំឲ្យរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកសកម្មភាពមីនជាសមាសធាតុមួយយ៉ាងសំខាន់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ។

ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១០-២០១៩ ឆ្លើយតបទៅនឹងការប្រឈមទាំងឡាយដែលតម្រូវឲ្យរាជរដ្ឋាភិបាលដោះស្រាយដើម្បីការអភិវឌ្ឍ និងផ្ដល់សុវត្ថិភាពដល់ប្រជាជនកម្ពុជាគ្រប់រូប។ ការកសាងផែនការយុទ្ធសាស្ត្រ គឺផ្អែកលើយុទ្ធសាស្ត្រដែលមានពីមុន ក៏ដូចជាចំណេះដឹង និងបទពិសោធដែលកម្ពុជាបានឆ្លងកាត់ក្នុងរយៈពេល ១៨ ឆ្នាំកន្លងមក ពីកិច្ចប្រឹងប្រែងបោសសម្អាតមីន។ យុទ្ធសាស្ត្រនេះក៏បានជួយដល់សំណើសុំពន្យារពេលបោសសម្អាតមីន រយៈពេល ១០ ឆ្នាំបន្ថែមទៀត ផ្អែកតាមមាត្រា៥ នៃអនុសញ្ញាស្ដីពីការហាមការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីនចោល ដែលកម្ពុជាបានក្លាយជារដ្ឋភាគីនៅដើមឆ្នាំ ២០០០។ ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន បានបង្កើតចេញជារូបរាងឡើងក្រោមការដឹកនាំរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីនបន្ទាប់ពីបានពិគ្រោះយោបល់ទូលំទូលាយ ជាមួយភាគីពាក់ព័ន្ធទាំងអស់ ក្នុងសកម្មភាពមីនកន្លងមក។

ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន គឺជាជំហានឆ្ពោះទៅមុខដ៏រឹងមាំ និងប្រកបដោយមហិច្ឆតា។ ការងារនេះតម្រូវឲ្យមានការលើកទឹកចិត្តដល់ប្រតិបត្តិករទាំងអស់ក្នុងការផ្ដល់នូវលទ្ធផលជាក់ស្ដែងរិះរកមធ្យោបាយក្នុងការដោះស្រាយនូវចំណុចខ្វះខាត ធ្វើការពិនិត្យឡើងវិញ និងកែលម្អនូវប្រព័ន្ធ និងធ្វើឲ្យប្រសើរឡើងនូវរាល់កិច្ចការរបស់យើង។ ផែនការយុទ្ធសាស្ត្រជាតិនេះ បានកសាងឡើងដោយភាគីពាក់ព័ន្ធទាំងអស់ ដើម្បីតម្រង់ធនធានបោសសម្អាតមីនឲ្យចំគោលដៅ និងធានាឲ្យអ្នកងាយរងគ្រោះជាងគេជាអ្នកទទួលផលពិតប្រាកដ។ ឯកសារនេះមានគោលបំណងផងដែរ ក្នុងការសម្រេចនូវគោលដៅអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាល ដោយធ្វើការពង្រឹងសមត្ថភាពជាតិ ដើម្បីចាត់ចែងការងារឲ្យមានប្រសិទ្ធភាព និងស៊ីចង្វាក់គ្នា និងដោយធ្វើឲ្យសម្រេចនូវការប្ដេជ្ញារបស់ខ្លួនក្នុងការអនុវត្តច្បាប់អន្តរជាតិ និងរក្សាបាននូវនិរន្តរភាពស្ថាប័នក្នុងការដោះស្រាយបញ្ហាមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ដែលនៅសេសសល់ក្នុងរយៈពេលវែង។

ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីននឹងត្រូវប្រើប្រាស់ជាឯកសារណែនាំយោងតែមួយគត់ សម្រាប់ដៃគូអភិវឌ្ឍពាក់ព័ន្ធទាំងអស់ដែលមានចំណាប់អារម្មណ៍ក្នុងការគាំទ្រសកម្មភាពមីននៅប្រទេសកម្ពុជា។ ផែនការយុទ្ធសាស្ត្រជាតិនេះ រំលេចនូវវិធានការ និងការអនុវត្តសកម្មភាពមួយចំនួន ដើម្បីសម្រេចឲ្យបាននូវគោលដៅជាយុទ្ធសាស្ត្រ។ ឯកសារនេះដាក់ចេញនូវសូចនាករ និងចំណុចដៅសំខាន់ៗ និងកំណត់ពេលវេលាជាក់លាក់ដែលនឹងជួយដល់ដៃគូអភិវឌ្ឍ ដើម្បីរៀបចំកម្មវិធី និងគម្រោងរបស់ខ្លួនសម្រាប់គាំទ្រយុទ្ធសាស្ត្រនេះ។ ដើម្បីឲ្យផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីនទទួលបានជោគជ័យ គឺតម្រូវឲ្យភាគីពាក់ព័ន្ធទាំងអស់សហការគ្នាមិនត្រឹមតែក្នុងអំឡុងពេលអនុវត្តផែនការយុទ្ធសាស្ត្រនេះប៉ុណ្ណោះទេ ប៉ុន្តែក្នុងការប្រមូលទិន្នន័យ និងព័ត៌មានដើម្បីត្រួតពិនិត្យលើការអនុវត្តយុទ្ធសាស្ត្រ និងវាយតម្លៃការរួមចំណែករបស់យុទ្ធសាស្ត្រនេះចំពោះគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ភាគីពាក់ព័ន្ធទាំងអស់ ទាំងក្នុងជួររាជរដ្ឋាភិបាល និងទាំងដៃគូអភិវឌ្ឍនឹងយកផែនការយុទ្ធសាស្ត្រនេះទៅប្រើប្រាស់ជាត្រីវិស័យ និងជាគោលការណ៍ណែនាំរួមមួយ ដើម្បីបង្កើនប្រសិទ្ធភាព និងលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមរបស់យើង។ កាយវិការនេះ នឹងបង្ហាញពីការប្ដេជ្ញាចិត្តរបស់យើង ចំពោះសេចក្ដីប្រកាសរួមស្ដីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ដែលយើងទាំងអស់គ្នាបានព្រមព្រៀង។ ខ្ញុំត្រៀមជាស្រេចដើម្បីសហការ ជាមួយភាគីពាក់ព័ន្ធទាំងអស់ ក្នុងការប្រែក្លាយកម្ពុជាឲ្យទៅជាប្រទេសមួយរួចចាកផុតពីផលប៉ះពាល់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម។

*រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១០*

**ហ៊ុន សែន**

# អក្សរកាត់

| | |
|---|---|
| ហ.ត. | ហិកតា |
| ម២ | ម៉ែត្រការ៉េ |
| គ.ម២ | គីឡូម៉ែត្រការ៉េ |
| ស.ផ.ស. | សំណល់ជាតិផ្ទុះពីសង្គ្រាម |
| អ.ហ.ផ.ម. | អនុសញ្ញាស្តីពីការហាមការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីនចោល |
| ផ.យ.អ.ជ. | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ |
| ផ.យ.ជ.ម. | ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន |
| អ.ធ.ម. | អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន |
| ក.ប.ម. | ក្រុមការងារបច្ចេកទេសចម្រុះសកម្មភាពមីន |
| ក.ស.អ.យ. | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ផ.ជ.ស.ជ. | ផែនការសកម្មភាពជាតិស្តីពីជនពិការរួមបញ្ចូលជនរងគ្រោះដោយសារមីន/ស.ផ.ស. |

# សេចក្តីសង្ខេប

បញ្ហាមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម(ស.ផ.ស.) នៅកម្ពុជា គឺជាកេរដំណែលដែលបន្សល់ទុកពីជម្លោះផ្ទៃក្នុង និងនៅក្នុងតំបន់ជាបន្តបន្ទាប់ ដែលបានអូសបន្លាយអស់ពេលយ៉ាងយូរ ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ ១៩៦០ រហូតដល់ចុងឆ្នាំ១៩៩៨។ ចរិតបញ្ហានៃការគំរាមដោយសារមីន/ស.ផ.ស. ក្នុងប្រទេសកម្ពុជា មានភាពស្មុគស្មាញយ៉ាងខ្លាំង។ តំបន់នៅជាប់ព្រំដែនថៃមានផលប៉ះពាល់ខ្លាំងដោយសារមីន និងតំបន់មួយភាគធំនៃភាគខាងកើតប្រទេស មានផលប៉ះពាល់មីនមធ្យម ប៉ុន្តែមានផលប៉ះពាល់ ស.ផ.ស. ច្រើន។ មីន/ស.ផ.ស. បានបង្កឲ្យមានចំនួនអ្នករងគ្រោះជាច្រើននាក់ ទាំងយោធា និង ជនស៊ីវិល ហើយក៏ជាឧបសគ្គដល់ការអភិវឌ្ឍជាតិផងដែរ។

ការបោសសម្អាតមីនបានចាប់ផ្តើមតាំងពីឆ្នាំ ១៩៧៩ នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ដោយកងទ័ពប្រជាជនបដិវត្តកម្ពុជាពិសេសកងអនុសេនាធំវិរនារីដោះមីន ដែលបានរំដោះផ្ទៃដីជាច្រើនពាន់ហិកតា បានរកឃើញ និងបំផ្លាញមីន/ស.ផ.ស. ជាច្រើនម៉ឺនគ្រាប់ ដើម្បីផ្តល់សុវត្ថិភាពក្នុងការតាំងទីលំនៅ និងធ្វើកសិកម្ម ទោះបីពេលនោះពុំមានថវិកាជាដុំកំភួន និងសម្ភារៈបច្ចេកទេសទំនើបក៏ដោយ។ ប៉ុន្តែការចាប់ផ្តើមបោសសម្អាតមីនមនុស្សធម៌ជាផ្លូវការនៅកម្ពុជា និងការបដិសន្ធិនៃកម្មវិធីសកម្មភាពមីនពេញលេញ គឺទើបនឹងចាប់ផ្តើមនៅឆ្នាំ ១៩៩២។

ការងារអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស. បានចាប់ផ្តើមនៅឆ្នាំ ១៩៩៣ ហើយផ្តោតលើការផ្តល់ការយល់ដឹង អំពីមីន/ស.ផ.ស. ដល់ជនមាតុភូមិនិវត្ត និងប្រជាជនបែកខ្ញែកភូមិឋានដែលបានតាំងទីលំនៅ នៅតំបន់ដែលមានការគំរាមក្រោយពីការបញ្ចប់ទៅនូវជម្លោះប្រដាប់អាវុធ។ នៅឆ្នាំ ១៩៩៨ សកម្មភាពបោសសម្អាតមីនត្រូវបានពង្រីកយ៉ាងខ្លាំង ហើយការបោសសម្អាតមីនត្រូវបានអនុវត្តដោយប្រតិបត្តិករបោសសម្អាតមីនធំៗ៤ គឺ៖ កងយោធពលខេមរភូមិន្ទ មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា អង្គការហាឡូត្រាស្ត និងអង្គការម៉ែក។ នៅឆ្នាំ ១៩៩៧ កម្ពុជាបានចុះហត្ថលេខា និងបានក្លាយជារដ្ឋភាគីនៃ អ.ហ.ផ.ម. នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០០០។ នៅខែកញ្ញា ឆ្នាំ២០០០ រាជរដ្ឋាភិបាលបានបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (អ.ជ.ម.) ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាជាប្រធាន ដោយមានការប្រមើលឃើញនូវតម្រូវការផ្លាស់ប្តូរពីបរិបទនៃការងារសង្គ្រោះបន្ទាន់ និងការងើបឡើងវិញពីសង្គ្រាមថ្មីៗមកគិតគូរអំពីការអភិវឌ្ឍយូរអង្វែង ដោយផ្តោតលើការគ្រប់គ្រងការធ្វើផែនការ និងការសម្របសម្រួលការងារក្នុងវិស័យមីនមួយ ដែលមានអភិក្រមបែបគ្រប់ជ្រុងជ្រោយវិញ។ អ.ជ.ម. មានភារកិច្ចទទួលខុសត្រូវក្នុងការធ្វើនិយតកម្ម និងសម្របសម្រួលសកម្មភាពមីននៅទូទាំងព្រះរាជាណាចក្រកម្ពុជា ហើយដើមឡើយក៏មានអាណត្តិលើការងារសម្របសម្រួល និងតាមដានការជួយសង្គ្រោះជនពិការដោយសារមីនផងដែរ។ ចាប់តាំងពីដើមទីកម្ពុជាបានទទួលស្គាល់នូវភាពចាំបាច់ក្នុងការបញ្ចូលតម្រូវការរបស់សហគមន៍ទៅក្នុងការកំណត់អាទិភាពបោសសម្អាតមីន ដើម្បីកាត់បន្ថយគ្រោះថ្នាក់ឲ្យបានខ្លាំងក្លាដោយបានបង្កើតអង្គភាពផែនការប្រើប្រាស់ដីមានមីននៅឆ្នាំ ១៩៩៩ និងគណៈកម្មាធិការសកម្មភាពមីនខេត្ត និងអង្គភាពផែនការសកម្មភាពមីននៅចុងឆ្នាំ ២០០៤។

ចាប់ពីឆ្នាំ១៩៩២ ដល់ឆ្នាំ២០០៩ កម្ពុជាសម្រេចបានសមិទ្ធផលជាច្រើនក្នុងនោះរួមមានការបោសសម្អាតមីននៅទូទាំងប្រទេសបានផ្ទៃដី ៥២.៩១៨ហ.ត. រកឃើញ និងបំផ្លាញមីនប្រឆាំងមនុស្ស ៨៦០.១៥៩គ្រាប់ មីនប្រឆាំងរថក្រោះ ១៩.៩៥២គ្រាប់ និងសំណល់ជាតិផ្ទុះពីសង្គ្រាម (ស.ផ.ស.) ១.៩០៧.៦២១គ្រាប់ សម្រាប់ការតាំងលំនៅឋាន ការធ្វើកសិកម្ម និងការកសាងហេដ្ឋារចនាសម្ព័ន្ធជាច្រើន។ ជាមួយនេះ យើងបានកាត់បន្ថយចំនួនជនរងគ្រោះពី ៤.៣២០នាក់ ក្នុងឆ្នាំ១៩៩៦ ចុះមកនៅត្រឹម ២៤៤នាក់ ក្នុងឆ្នាំ ២០០៩។ លទ្ធផលទាំងនេះអាចសម្រេចទៅបាន ក៏ដោយសារមានការគាំទ្រទាំងបច្ចេកទេស សម្ភារៈ និងថវិកា ពីរាជរដ្ឋាភិបាល និងសហគមន៍អន្តរជាតិ។

ទោះយ៉ាងនេះក្តី ក៏បញ្ហាមីន/ស.ផ.ស. នៅតែជាឧបសគ្គដល់ការរស់នៅរបស់ប្រជាជន និងការអភិវឌ្ឍជាតិនៅឡើយ។ អាស្រ័យហេតុនេះ ទើបរាជរដ្ឋាភិបាលកម្ពុជា បានកំណត់យកសកម្មភាពមីនធ្វើជាគោលដៅទី៩ នៃគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា ជាសកម្មភាពមួយនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងជាសមាសធាតុមួយយ៉ាងសំខាន់ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ។ នៅខែធ្នូ ឆ្នាំ២០០៩ កន្លងមក កិច្ចប្រជុំត្រួតពិនិត្យលើកទី២ នៃរដ្ឋភាគីអនុសញ្ញាអូតាវ៉ា បានសម្រេចគាំទ្រសំណើរបស់កម្ពុជា ដើម្បីបន្តសកម្មភាពមីនរយៈពេល ១០ឆ្នាំទៀត។

យោងតាមអាណត្តិ ១០ឆ្នាំថ្មី នៃការអនុវត្តមាត្រា៥ នៃ អ.ហ.ផ.ម. កម្ពុជាត្រូវធ្វើការបោសសម្អាតមីនប្រឆាំងមនុស្សទាំងស្រុង លើផ្ទៃដី ៦៤៨,៨ គ.ម$^{២}$ និងផ្ទៃដីសង្ស័យថាមានមីន ១.០៩៧,៨ គ.ម$^{២}$ ដែលចាំបាច់ត្រូវធ្វើការរំដោះតាមរយៈការស្រាវជ្រាវទិន្នន័យមូលដ្ឋាន និងការ

ស្រាវជ្រាវបច្ចេកទេស។ ដើម្បីសម្រេចផែនការនេះ កម្ពុជាត្រូវការថវិកាចំនួន ៤៥៥ លានដុល្លារ។ លើសពីនេះទៀត បញ្ហា ស.ផ.ស. ដែលជាសំណល់នៃគ្រាប់ផ្លោង គ្រាប់រ៉ុក្កែត និងគ្រាប់ទម្លាក់ពីអាកាស នៅមានទំហំយ៉ាងធំ។ យោងតាមព័ត៌មានដែលទទួលបានពី ក្រសួងការបរទេសសហរដ្ឋអាមេរិកបានឲ្យដឹងថា គ្រាន់តែការទម្លាក់គ្រាប់ពីលើយន្តហោះចម្បាំងនៅកម្ពុជាមានចំនួនជាង ២,៧៥ លានតោន ក្នុងចន្លោះពីឆ្នាំ១៩៦៥-១៩៧៥។ ដើម្បីដោះស្រាយបញ្ហា ស.ផ.ស. នេះ កម្ពុជាត្រូវការកញ្ចប់ថវិកាដោយឡែកបន្ថែមលើថវិកាសម្រាប់ដោះស្រាយបញ្ហាគ្រាប់មីន។

ដើម្បីធ្វើឲ្យសម្រេចបាននូវគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងបំពេញបាននូវកាតព្វកិច្ចនានានៃអនុសញ្ញាអូតាវ៉ា អ.ធ.ម. រួមជាមួយប្រតិបត្តិករបោសសម្អាតមីន និងភ្នាក់ងារជាដៃគូពាក់ព័ន្ធទាំងអស់ បានកសាងផែនការយុទ្ធ-សាស្ត្រជាតិសកម្មភាពមីន (ផ.យ.ជ.ម.) រួមមួយដោយផ្អែកលើឯកសារយុទ្ធសាស្ត្រនានាមានពីមុន បទពិសោធលទ្ធផលសម្រេចបានកន្លងមក របាយការណ៍សិក្សាស្តីពីដំណើរឆ្ពោះទៅរកការកសាងផ.យ.ជ.ម. ថ្មីមួយ សម្រាប់កម្ពុជា និងលទ្ធផលនៃសិក្ខាសាលាកសាងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីនកាលពីខែកក្កដាឆ្នាំ២០០៩។ រយៈពេលសម្រាប់អនុវត្តយុទ្ធសាស្ត្រថ្មី ២០១០-២០១៩ នេះ ក៏ស្របគ្នានឹងវដ្តនៃឯកសារផែនការជាតិសំខាន់ៗផងដែរ ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបន្ទាប់ ២០១៤-២០១៨។

ស្នូលនៃ ផ.យ.ជ.ម. រួមមានគោលដៅចំនួនបួន។ គោលដៅទាំងបួននោះគឺ ទី១ កាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស. និងផលប៉ះពាល់អវិជ្ជមានដទៃទៀត ទី២ រួមចំណែកដល់ការជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ទី៣ ធានានិរន្តរភាពសមត្ថភាពជាតិក្នុងការដោះស្រាយបញ្ហាមីន/ស.ផ.ស. ដែលនៅសេសសល់ និង ទី៤ លើកកម្ពស់ស្ថិរភាព និងការរំសាយសព្វាវុធនៅក្នុងតំបន់ និងលើឆាកអន្តរជាតិ។

ដើម្បីអនុវត្ត ផ.យ.ជ.ម. ឲ្យបានជោគជ័យ កម្ពុជាត្រូវចាត់វិធានការអនុវត្ត ដូចជា ទី១ ធ្វើការស្រាវជ្រាវទិន្នន័យមូលដ្ឋាននៅក្នុងស្រុកចំនួន ១២២ ដែលរងផលប៉ះពាល់ដោយសារមីន/ស.ផ.ស. ឲ្យបានចប់នៅឆ្នាំ២០១២ ទី២ អនុវត្តវិធីសាស្ត្រកាត់បន្ថយផ្ទៃដីសង្ស័យ ដោយផ្អែកតាមទិន្នន័យស្រាវជ្រាវមូលដ្ឋាន ទី៣ បញ្ជ្រាបផែនការសកម្មភាពមីនជាមួយនឹងផែនការថ្នាក់ក្រោមជាតិ ដោយធ្វើការចាត់អាទិភាពចំការមីនផ្អែកតាមទិន្នន័យស្រាវជ្រាវមូលដ្ឋាន និងតម្រូវការរបស់សហគមន៍មូលដ្ឋានក្នុងការកាត់បន្ថយគ្រោះថ្នាក់ និងការអភិវឌ្ឍដើម្បីកំណត់ធនធានបោសសម្អាតមីនឲ្យចំទិសដៅ ទី៤ ពង្រឹងសមត្ថភាព និងការសម្របសម្រួលការងារសំខាន់ៗមួយចំនួន ដូចជាការរៀបចំផែនការការសម្របសម្រួលសកម្មភាពមីន ការបញ្ជ្រាបយេនឌ័រ ការគ្រប់គ្រងព័ត៌មាន និងការធានាគុណភាព ទី៥ ចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងរក្សាស្ថិរភាពក្នុងតំបន់ និងអន្តរជាតិដោយចូលរួមអនុវត្តនូវអនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិដែលកម្ពុជាជារដ្ឋភាគី ទី៦ ធ្វើការកាត់បន្ថយគ្រោះថ្នាក់ និងជួយសង្គ្រោះជនរងគ្រោះដោយសារមីន/ស.ផ.ស. និង ទី៧ រក្សានិរន្តរភាពសមត្ថភាពជាតិ។

ដើម្បីត្រួតពិនិត្យតាមដានលទ្ធផលសម្រេចបាន និងវឌ្ឍនភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន អ.ធ.ម. ត្រូវបង្កើតឲ្យមានយន្តការក្នុងការវាស់វែងលទ្ធផលសម្រេចបានធៀបនឹងគោលដៅសូចនាករ និងចំណុចដៅ ព្រមទាំងវិធានការអនុវត្ត ដែលបានលើកឡើងក្នុងយុទ្ធសាស្ត្រ។ ការវាយតម្លៃលើកទី១ នឹងត្រូវធ្វើឡើងនៅក្នុងឆ្នាំ ២០១៣ ហើយការជូនព័ត៌មាន និងការពិនិត្យវាយតម្លៃឡើងវិញឲ្យស្របទៅនឹង ផ.យ.អ.ជ. និងការត្រួតពិនិត្យវាយតម្លៃឡើងវិញចុងក្រោយ នឹងត្រូវធ្វើឡើងនៅក្នុងឆ្នាំ២០១៩។ ភ្នាក់ងារពាក់ព័ន្ធសកម្មភាពមីនទាំងអស់ត្រូវផ្តល់ទិន្នន័យ របាយការណ៍វឌ្ឍនភាពតាមការកំណត់ឲ្យ អ.ធ.ម. ដើម្បីកត់ត្រា និងធ្វើការវិភាគព្រមទាំងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ។

# សេចក្តីផ្តើម

១. សកម្មភាពមីននៅកម្ពុជាបានឈានមកដល់ដំណាក់កាលមួយយ៉ាងសំខាន់នាពេលបច្ចុប្បន្ននេះ។ ថ្វីបើកម្ពុជាសម្រេចបាននូវសមិទ្ធផលគួរឲ្យកត់សំគាល់ជាច្រើនក្នុងរយៈពេល ១៨ ឆ្នាំកន្លងមកយ៉ាងណាក្តី បញ្ហាប្រឈមដែលនៅសេសសល់នៅតែជាបញ្ហាដ៏ធំបំផុតមួយនៅក្នុងពិភពលោកនៅឡើយ គ្រាន់តែយើងមិនទាន់បានកំណត់ឲ្យជាក់លាក់អំពីទំហំនៃបញ្ហានៅឡើយ។ អត្រាគ្រោះថ្នាក់ដោយសារមីនប្រចាំឆ្នាំនៅតែមានកម្រិតខ្ពស់ ដែលធ្វើឲ្យកម្ពុជាស្ថិតនៅជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានគ្រោះថ្នាក់ខ្ពស់ជាងគេលើពិភពលោក។ នៅខែធ្នូ ឆ្នាំ២០០៩ កម្ពុជាបានទទួលការឯកភាពឲ្យបន្តអាណត្តិ ១០ឆ្នាំទៀត ក្នុងការអនុវត្តតាមមាត្រា៥ នៃអនុសញ្ញាស្តីពីការហាមការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីនចោល (អ.ហ.ផ.ម.)។ ម្យ៉ាងវិញទៀត សេចក្តីស្នើសុំធ្វើការបោសសម្អាតមីនជាបន្ទាន់ សម្រាប់សហគមន៍ ថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិនៅតែមានបរិមាណច្រើន។

២. ការពិចារណាទាំងឡាយខាងលើនេះ បានញ៉ាំងឲ្យរាជរដ្ឋាភិបាលកម្ពុជាដោយសហការជាមួយនឹងដៃគូអភិវឌ្ឍ ប្រតិបត្តិករ និងភាគីពាក់ព័ន្ធទាំងអស់ ធ្វើការបូកសរុបនូវស្ថានភាពកន្លងមក និងកំណត់នូវបញ្ហាប្រឈមជាគន្លឹះសំខាន់ៗដែលត្រូវដោះស្រាយ ព្រមទាំងធ្វើការពង្រឹងសមត្ថភាព ដើម្បីអនុវត្តឲ្យបានជោគជ័យលើការបោសសម្អាតមីន ក្នុងអាណត្តិ ១០ឆ្នាំបន្ត ស្របតាមមាត្រា៥ នៃ អ.ហ.ផ.ម. ដើម្បីកាត់បន្ថយអត្រាគ្រោះថ្នាក់ និងឈានទៅលុបបំបាត់ការគំរាមកំហែងដោយគ្រាប់មីនប្រឆាំងមនុស្សនៅកម្ពុជា ក្នុងន័យរួមចំណែកកាត់បន្ថយភាពក្រីក្រ និងជំរុញកំណើនសេដ្ឋកិច្ច។

៣. ទន្ទឹមនឹងបញ្ហាគ្រាប់មីនប្រឆាំងមនុស្ស កម្ពុជាក៏កំពុងប្រឈមនឹងការគំរាមយ៉ាងធ្ងន់ធ្ងរពី ស.ផ.ស. ដែលនៅតែបង្កគ្រោះថ្នាក់ជាបន្តបន្ទាប់ដល់ប្រជាពលរដ្ឋ និងរាំងស្ទះដល់ការអភិវឌ្ឍលើគ្រប់វិស័យក្នុងសង្គម។ ជាងនេះទៀត បើប្រៀបធៀបទៅនឹងបញ្ហាមីនប្រឆាំងមនុស្ស ស.ផ.ស. ជាបញ្ហាប្រឈមសម្រាប់រយៈពេលយូរអង្វែងនៅកម្ពុជា។

៤. ជារួមការរៀបចំឯកសារ ផ.យ.ជ.ម. នេះបានផ្តើមចេញពីការទទួលស្គាល់ដោយភាគី និងក្រសួងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃវិស័យសកម្មភាពមីននាពេលបច្ចុប្បន្ននៅកម្ពុជា។ ផ.យ.ជ.ម. នេះ បានប្រមូលផ្តុំផងដែរនូវយុទ្ធសាស្ត្របោសសម្អាតមីន/ស.ផ.ស[១] យុទ្ធសាស្ត្រអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស. ដែលមានស្រាប់ និងបានផ្តោតលើកិច្ចគាំពារដល់ជនរងគ្រោះដោយសារមីន/ស.ផ.ស. ដែលជាផ្នែកមួយ នៃឯកសារផែនការសកម្មភាពជាតិស្តីពីជនពិការរួមបញ្ចូលជនរងគ្រោះដោយសារមីន/ស.ផ.ស. (ផ.ជ.ស.ជ.)។ ផ.យ.ជ.ម. នេះ នឹងជួយដល់ការអនុវត្តអាណត្តិ១០ឆ្នាំថ្មី នៃការបោសសម្អាតមីន ព្រមទាំងជួយក្នុងការបញ្ជ្រាបកម្មវិធីសកម្មភាពមីនទៅក្នុងយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំផែនការ និងការចាត់អាទិភាព[២]។

៥. ការបោសសម្អាតមីនបានចាប់ផ្តើមតាំងពីឆ្នាំ ១៩៧៩ នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ដោយកងទ័ពប្រជាជនបដិវត្តកម្ពុជាពិសេសកងអនុសេនាធំវិរនារីដោះមីន ដែលបានរំដោះផ្ទៃដីជាច្រើនពាន់ហិកតា បានរកឃើញ និងបំផ្លាញមីន/ស.ផ.ស. ជាច្រើនម៉ឺនគ្រាប់ ដើម្បីផ្តល់សុវត្ថិភាពក្នុងការតាំងទីលំនៅ និងធ្វើកសិកម្មទោះបីពេលនោះពុំមានថវិកាជាជុំកំភួន និងសម្ភារៈបច្ចេកទេសទំនើបក៏ដោយ។ ប៉ុន្តែការចាប់ផ្តើមបោសសម្អាតមីនមនុស្សធម៌ជាផ្លូវការនៅកម្ពុជា និងការបដិសន្ធិនៃកម្មវិធីសកម្មភាពមីនពេញលេញ គឺទើបនឹងចាប់ផ្តើមនៅឆ្នាំ១៩៩២ នេះទេ។ នៅឆ្នាំ១៩៩៨ សកម្មភាពបោសសម្អាតមីនត្រូវបានពង្រីកយ៉ាងខ្លាំង ហើយការបោសសម្អាតមីននេះត្រូវបានអនុវត្តដោយប្រតិបត្តិករបោសសម្អាតមីនធំ ៤គឺ កងយោធពលខេមរភូមិន្ទ មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា អង្គការហាឡូត្រាស្ត និងអង្គការម៉ែក។

---

[១] សំណល់ជាតិផ្ទុះពីសង្គ្រាម (ERW) រួមមានយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (UXO) និងជាតិផ្ទុះដែលត្រូវបានបោះបង់ចោល (AXO)

[២] មើលរបាយការណ៍ការសិក្សាខែសីហាឆ្នាំ២០០៨ របស់ GICHD/CMAA ស្តីពី "ការឆ្លោះទៅរកការកសាងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន"

៦. កម្ពុជាបានចុះហត្ថលេខានៅឆ្នាំ១៩៩៧ និងបានក្លាយជារដ្ឋភាគីនៃអនុសញ្ញា អ.ហ.ផ.ម. នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០០០។ នៅខែកញ្ញា ឆ្នាំ២០០០ រាជរដ្ឋាភិបាលបានបង្កើត អ.ធ.ម. ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្រ្តី នៃព្រះរាជាណាចក្រកម្ពុជា ជាប្រធាន ដើម្បីធ្វើនិយតកម្មសម្របសម្រួល និងត្រួតពិនិត្យសកម្មភាពមីននៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

៧. ដើម្បីធ្វើឲ្យសម្រេចបាននូវគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា គោលនយោបាយនៃយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ និងឯកសារសំណើសុំពន្យារពេលបោសសម្អាតមីន១០ឆ្នាំបន្ត អ.ធ.ម. ប្រតិបត្តិករបោសសម្អាតមីន និងភ្នាក់ងារជាដៃគូពាក់ព័ន្ធទាំងអស់បានកសាងផែនការយុទ្ធសាស្រ្តជាតិសកម្មភាពមីនរួមមួយ ដោយផ្អែកលើឯកសារយុទ្ធសាស្រ្តនានាមានពីមុន បទពិសោធ មេរៀន លទ្ធផលសម្រេចបានកន្លងមក របាយការណ៍សិក្សាស្តីពី ដំណើរឆ្ពោះទៅរកការកសាងផែនការយុទ្ធសាស្រ្តជាតិសកម្មភាពមីនថ្មីមួយ សម្រាប់កម្ពុជា ដោយ អ.ធ.ម. និងមជ្ឈមណ្ឌលបោសសម្អាតមីនមនុស្សធម៌អន្តរជាតិហ្សឺណែវ កាលពីខែសីហា ឆ្នាំ២០០៨ និងលទ្ធផលសិក្ខាសាលាកសាងផែនការយុទ្ធសាស្រ្តជាតិសកម្មភាពមីនកាលពីខែកក្កដា ឆ្នាំ២០០៩ ដែលបានរៀបចំឡើងដោយអាជ្ញាធរមីនកម្ពុជា ដោយមានការគាំទ្រពីកម្មវិធីអភិវឌ្ឍសហប្រជាជាតិ ។

# ជំពូកទី ១

# ស្ថានភាពមីន/ស.ផ.ស. បច្ចុប្បន្ននៅកម្ពុជា

១. បញ្ហាមីន/ស.ផ.ស. នៅកម្ពុជា គឺជាកេរដំណែលដែលបន្សល់ទុកពីជម្លោះផ្ទៃក្នុង និងនៅក្នុងតំបន់ជាបន្តបន្ទាប់ដែលបានអូសបន្លាយអស់ពេលយ៉ាងយូរ ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍១៩៦០ រហូតដល់ចុងឆ្នាំ១៩៩៨។ ចរិតបញ្ហានៃការគំរាមដោយសារមីន/ស.ផ.ស. ក្នុងប្រទេសកម្ពុជាមានភាពស្មុគស្មាញយ៉ាងខ្លាំង។ តំបន់នៅជាប់ព្រំដែនថៃ មានផលប៉ះពាល់ខ្លាំងដោយសារមីន និងតំបន់មួយភាគធំនៃភាគខាងកើតប្រទេសមានផលប៉ះពាល់មីនមធ្យម ប៉ុន្តែមានផលប៉ះពាល់ស.ផ.ស. ច្រើន។ មីន/ស.ផ.ស. បានបង្កឲ្យមានចំនួនអ្នកគ្រោះថ្នាក់ជាច្រើននាក់ ទាំងយោធា និងជនស៊ីវិល និងក៏ជាឧបសគ្គដល់ការអភិវឌ្ឍជាតិផងដែរ។ មីន/ស.ផ.ស. នៅតែបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់មនុស្ស សង្គម និងសេដ្ឋកិច្ចនៅកម្ពុជា។ បើទោះបីជា យើងបានកាត់បន្ថយអត្រាគ្រោះថ្នាក់ដោយសារមីន/ស.ផ.ស. ពីកម្រិតដ៏ខ្ពស់ដែលមានជនរងគ្រោះ ៤.៣២០នាក់ នៅឆ្នាំ១៩៩៦ ចុះមកត្រឹម ២៤៤នាក់ នៅឆ្នាំ២០០៩ ក៏ដោយ ក៏ចំនួននេះនៅតែជាប់ក្នុងលំដាប់ខ្ពស់បំផុតមួយ ក្នុងពិភពលោក។

២. យោងតាមឯកសារអាណត្តិ ១០ឆ្នាំថ្មី នៃការអនុវត្តមាត្រា៥ នៃ អ.ហ.ផ.ម. កម្ពុជាបានព្យាករថានៅមានផ្ទៃដីប្រហែល ៦៤៨,៨ គ.ម២ ដែលត្រូវធ្វើការបោសសម្អាតមីនក្នុងរយៈពេល ១០ឆ្នាំទៀត និងផ្ទៃដីប្រមាណ ១.០៩៧,៨ គ.ម២ ដែលជាតំបន់សង្ស័យថាមានមីន ដែលចាំបាច់ត្រូវធ្វើការរំដោះតាមរយៈការស្រាវជ្រាវទិន្នន័យមូលដ្ឋាន និងការស្រាវជ្រាវបច្ចេកទេស ។

៣. បន្ថែមលើបញ្ហាមីន ដូចមានចែងត្រង់ចំណុច ២ខាងលើ បញ្ហា ស.ផ.ស. ដែលជាសំណល់នៃគ្រាប់ផ្លោង គ្រាប់រ៉ុក្កែត និងគ្រាប់ទម្លាក់ពីអាកាស មានទំហំធំផង។ យោងតាមព័ត៌មានដែលទទួលបានពីក្រសួងការបរទេសសហរដ្ឋអាមេរិកបានឲ្យដឹងថា គ្រាន់តែការទម្លាក់គ្រាប់ពីលើយន្តហោះចម្បាំងនៅកម្ពុជា មានចំនួនជាង ២,៧៥លានតោន ក្នុងចន្លោះពីឆ្នាំ ១៩៦៥-១៩៧៥។

៤. ការស្រាវជ្រាវលំដាប់ជាតិកម្រិត១ នៅឆ្នាំ២០០២ បានរកឃើញថាចំនួន ៦.៤១៦ភូមិ (ប្រហែល៤៦% នៃភូមិទូទាំងប្រទេស) មានផលប៉ះពាល់ដោយសារមីន/ស.ផ.ស. ដែលបានធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជន។ គម្រោងស្តារផ្លូវថ្នល់ ការកសាងហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានាឡើងវិញមានដំណើរការយឺតយ៉ាវ ហើយការរានដីតាំងទីលំនៅរបស់ប្រជាជនទៅកាន់តំបន់ថ្មី ក៏នៅមានការគំរាមកំហែងដោយសារមីន/ស.ផ.ស. ផងដែរ។ ការវិនិយោគឯកជន ឬសាធារណៈមានផលប៉ះពាល់ខ្លះ ដោយសារមីន/ស.ផ.ស. ដូចជា ការជីករករ៉ែ វិស័យទេសចរណ៍ និងការការពារបរិស្ថានជាដើម។

# ជំពូកទី ២

# ក្របខ័ណ្ឌយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំឡើងដោយ អ.ធ.ម. ដោយមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធសកម្មភាពមីនទាំងអស់។ ការកសាង ផ.យ.ជ.ម. នេះ គឺផ្អែកលើយុទ្ធសាស្ត្រ[៣] បទពិសោធ និងលទ្ធផលដែលមានពីមុនមក ដោយព្យាយាមបំពេញចំណុចខ្វះខាត និងកែលម្អលើផ្នែកមួយចំនួននៃសកម្មភាពមីន។ ផ.យ.ជ.ម. នេះឆ្លុះបញ្ចាំងពីចក្ខុវិស័យរបស់រាជរដ្ឋាភិបាលសម្រាប់សកម្មភាពមីនក្នុងរយៈពេល ១០ឆ្នាំខាងមុខ និងមានគោលបំណងធ្វើឲ្យបានសម្រេចនូវគោលដៅដែលមានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិ និងឯកសារគោលនយោបាយនានាដូចជា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២[៤] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ[៥] និងគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជាទី៩ ស្តីពីសកម្មភាពមីន និងការជួយសង្គ្រោះជនរងគ្រោះដោយសារមីន។ ផ.យ.ជ.ម. នេះក៏មានទិសដៅចូលរួមចំណែកដល់របៀបវារៈគោលនយោបាយរបស់កម្ពុជាស្តីពី ការលើកកម្ពស់ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ដោយផ្តល់ជាក្របខ័ណ្ឌដែលធានានូវភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា និងអាចឲ្យដៃគូអភិវឌ្ឍតម្រង់ទិសហិរញ្ញប្បទានសហប្រតិបត្តិការរបស់ខ្លួន ទៅនឹងការងារអាទិភាពនានារបស់ជាតិ និងការពង្រឹងប្រព័ន្ធជាតិ និងការចាត់ចែងនូវធនធានសម្រាប់សកម្មភាពមីនឲ្យប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ យន្តការនេះអាចធ្វើឲ្យវិស័យសកម្មភាពមីនអាចឈានទៅអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីប្រកបដោយសង្គតិភាពក្នុងការគ្រប់គ្រងចាត់ចែងធនធានបោសសម្អាតមីន/ស.ផ.ស.។

ផ.យ.ជ.ម. ត្រូវបានរៀបចំឡើងសម្រាប់រយៈពេល ១០ឆ្នាំ (២០១០-២០១៩) គឺត្រូវគ្នានឹងអាណត្តិ១០ឆ្នាំថ្មី នៃការបោសសម្អាតមីននៅកម្ពុជា យោងតាមមាត្រា៥ នៃ អ.ហ.ផ.ម. ក៏ដូចជាស្របគ្នាទៅនឹងវដ្តនៃឯកសារផែនការជាតិសំខាន់ៗផងដែរដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបន្ទាប់ ២០១៤-២០១៨ និងគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា ២០១៥។

## ២.១. ទស្សនវិស័យ

ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១០ ២០១៩ មានទស្សនវិស័យធ្វើឲ្យកម្ពុជាចាកផុតពីការគំរាមកំហែងដោយសារមីនប្រឆាំងមនុស្ស និងកាត់បន្ថយការគំរាមកំហែងដោយសារមីនប្រឆាំងរថក្រោះ និង ស.ផ.ស. ឲ្យបានជាអតិបរិមា ព្រមទាំងលើកកម្ពស់សិទ្ធិជនរងគ្រោះដោយសារមីន/ស.ផ.ស. និងសហគមន៍ដែលរងផលប៉ះពាល់។

---

3 បច្ចុប្បន្ន ផែនការយុទ្ធសាស្ត្រទាំងនេះនៅដាច់ដោយឡែកពីគ្នាដូចជា៖ ផែនការយុទ្ធសាស្ត្រសកម្មភាពមីន(បោះពុម្ពលើកទី៣ ឆ្នាំ២០០៥) ផែនការសកម្មភាពមីន៥ឆ្នាំ (២០០៥-២០០៩) យុទ្ធសាស្ត្រជាតិស្តីពីសំណល់ជាតិផ្ទុះពីសង្គ្រាម(២០០៩-២០១៥) ផែនការយុទ្ធសាស្ត្រស្តីពីការអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស. (បោះពុម្ពលើកទី១ ឆ្នាំ២០០៦) ផែនការសកម្មភាពជាតិស្តីពីជនពិការរួមបញ្ចូលជនរងគ្រោះដោយសារមីន/ស.ផ.ស. (២០០៩-២០១១)។

4 យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជាដំណាក់កាលទី២។ ក្នុងនីតិកាលទី៤ នេះ ការបោសសម្អាតមីន/ ស.ផ.ស. នៅតែជាអាទិភាពរបស់រាជរដ្ឋាភិបាល ពិសេសនៅតំបន់ដាច់ស្រយាល តំបន់ដែលកសិករខ្វះដី និងតំបន់មានសក្តានុពលខ្ពស់ ក្នុងការអភិវឌ្ឍកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ។ ទន្ទឹមនឹងនេះ សកម្មភាពបោសសម្អាតមីន/ស.ផ.ស. ត្រូវផ្សារភ្ជាប់នឹងគោលការណ៍បែងចែកដីបោសសម្អាតរួចហើយនេះ ឲ្យដល់ប្រជាកសិករដែលខ្វះដីពិតប្រាកដប្រកបដោយសមធម៌។

5 ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ គឺ "ជាឯកសារទោលដែលគ្របដណ្តប់ទិសដៅ និងយុទ្ធសាស្ត្រជាអាទិភាពនានារបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយនូវភាពក្រីក្រ និងធ្វើឲ្យសម្រេចបានឆាប់រហ័សតាមគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា និងគោលដៅអភិវឌ្ឍសេដ្ឋកិច្ចសង្គមសម្រាប់ជាប្រយោជន៍ដល់ជនកម្ពុជាគ្រប់រូប"។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០០៦-២០១០ ត្រូវបានធ្វើបច្ចុប្បន្នភាពគ្របដណ្តប់រយៈពេល ២០០៩-២០១៣។ យុទ្ធសាស្ត្រជាតិនេះ មានចែងពីបញ្ហាមីនដែលជាតម្រូវការមួយក្នុងការកាត់បន្ថយគ្រោះថ្នាក់ និងការលុបបំបាត់ឧបសគ្គរាំងស្ទះដល់កិច្ចអភិវឌ្ឍ។ ឯកសារនេះក៏បានរំលេចនូវចំណុចដៅទាក់ទងនឹងការកាត់បន្ថយអត្រាគ្រោះថ្នាក់ និងសមាមាត្រនៃទំហំផ្ទៃដីដែលត្រូវបោសសម្អាត។ ផ.យ.អ.ជ. បន្ទាប់នឹងគ្របដណ្តប់សម្រាប់រយៈពេល ២០១៤-២០១៨។

## ២.២. បេសកកម្ម

ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១០-២០១៩ មានបេសកកម្មធានាឲ្យការរស់នៅរបស់ប្រជាពលរដ្ឋគ្រប់រូប បុរស ស្ត្រី និងកុមារ ព្រមទាំងការអភិវឌ្ឍ អាចប្រព្រឹត្តទៅដោយសុវត្ថិភាពគ្រប់ទីកន្លែង និងធានាសម្របសម្រួលការផ្តល់សេវា ការផ្តល់ហិរញ្ញប្បទាន សហប្រតិបត្តិការ និងការប្រើប្រាស់ ថវិកាសម្រាប់សកម្មភាពមីន ប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាពថែមទៀត។

## ២.៣. គោលដៅ

**គោលដៅទី១: កាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស. និងផលប៉ះពាល់អវិជ្ជមានដទៃទៀតដោយ៖**

- ❖ បែងចែកធនធានបោសសម្អាតមីន ឲ្យដល់កន្លែងដែលរងផលប៉ះពាល់ខ្ពស់ជាងគេ
- ❖ ផ្តល់ការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន/ស.ផ.ស. ប្រកបដោយប្រសិទ្ធភាព។

**គោលដៅទី២: រួមចំណែកដល់ការជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រដោយ៖**

- ❖ គាំទ្រដល់អាទិភាពនៃការអភិវឌ្ឍមូលដ្ឋាននៅតាមសហគមន៍ដែលទទួលរងផលប៉ះពាល់ដោយសារមីន ស.ផ.ស.
- ❖ គាំទ្រដល់អាទិភាពនៃការអភិវឌ្ឍទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ❖ គាំទ្រដល់ជនរងគ្រោះដោយសារមីន/ស.ផ.ស. និងគ្រួសាររបស់ពួកគេឲ្យទទួលបានការថែទាំសុខភាព និងការស្តារលទ្ធភាពពលកម្ម និងការគាំទ្រសម្រាប់ជីវភាពរស់នៅ
- ❖ គាំទ្រដល់ដំណើរការរដ្ឋបាលដីធ្លី ដើម្បីធានាសិទ្ធិប្រើប្រាស់ដីស្របច្បាប់របស់អ្នកដែលត្រូវទទួលផលលើដីដែលបោសសម្អាតមីនរួច។

**គោលដៅទី៣: ធានានូវនិរន្តរភាពសមត្ថភាពជាតិក្នុងការដោះស្រាយបញ្ហាមីន/ស.ផ.ស. នៅសេសសល់ដោយ៖**

- ❖ ពិនិត្យឡើងវិញនូវក្របខ័ណ្ឌស្ថាប័នសម្រាប់ដោះស្រាយបញ្ហាមីន/ស.ផ.ស. ដែលនៅសេសសល់
- ❖ រកឲ្យឃើញ និងដោះស្រាយការខ្វះចន្លោះសមត្ថភាព
- ❖ រក្សានិរន្តរភាពក្របខ័ណ្ឌសមត្ថភាពជាតិ។

**គោលដៅទី៤: លើកកម្ពស់ស្ថិរភាព និងការរំសាយសព្វាវុធនៅក្នុងតំបន់ និងលើឆាកអន្តរជាតិដោយ៖**

- ❖ គាំទ្រអនុសញ្ញា អ.ហ.ផ.ម.
- ❖ គាំទ្រការចុះហត្ថលេខា លើពិធីសារទី៥ ស្តីពី ស.ផ.ស. នៃអនុសញ្ញាស្តីពីសព្វាវុធធម្មតាមួយចំនួន
- ❖ គាំទ្រការងារបោះបង្គោលព្រំដែន
- ❖ គាំទ្រការងារបោសសម្អាតមីន ក្នុងក្របខ័ណ្ឌបេសកកម្មរក្សាសន្តិភាព អង្គការសហប្រជាជាតិ
- ❖ ផ្លាស់ប្តូរបទពិសោធនៅក្នុងកម្រិតជាតិ តំបន់ និងអន្តរជាតិ។

សកម្មភាពចំណុចដៅ និងសូចនាករឆ្លើយតបទៅនឹងគោលដៅខាងលើ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ក នៃ ផ.យ.ជ.ម. នេះ។

## ២.៤. ស្ថាប័ន និង ការសម្របសម្រួល

២.៤.១. បច្ចុប្បន្ន កម្ពុជាមានចេនាសម្ព័ន្ធវិស័យសកម្មភាពមីនច្បាស់លាស់របស់ខ្លួន។ អ.ជ.ម. ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ដែលមានប្រមុខរាជរដ្ឋាភិបាលជាប្រធាន មានអនុប្រធាន និងអគ្គលេខាធិការជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងការងារប្រចាំថ្ងៃ។ អ.ជ.ម. ទទួលខុសត្រូវលើការងារសម្របសម្រួល តាមដានត្រួតពិនិត្យ និងធ្វើនិយតកម្មរាល់សកម្មភាពមីន ក៏ដូចជាការកសាងផែនការយុទ្ធសាស្ត្រ និងផែនការការងារដើម្បីសម្រេចឲ្យបាននូវអាទិភាពដែលបានកំណត់ដោយគោលនយោបាយអភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។ អ.ជ.ម. បានរៀបចំនូវគោលនយោបាយ ស្តង់ដា និងគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងកម្មវិធីសកម្មភាពមីននៅកម្ពុជា។ ក្នុងន័យនេះ អ.ជ.ម. គឺជាស្ថាប័នដែលទទួលខុសត្រូវក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យលើការអនុវត្ត ផ.យ.ជ.ម.។

២.៤.២. ក្រុមការងារបច្ចេកទេសចម្រុះសកម្មភាពមីន(ក.ប.ម.) ជាយន្តការពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ លើបញ្ហាគោលនយោបាយនានាក្នុងគោលបំណងធ្វើឲ្យកាន់តែប្រសើរថែមទៀតនូវការសម្របសម្រួល ការតម្រឹម និងសុខដុមនីយកម្មហិរញ្ញប្បទានសហប្រតិបត្តិការនៅក្នុងវិស័យសកម្មភាពមីន។ អាណត្តិរបស់ ក.ប.ម. គឺជួយគាំទ្រដល់រាជរដ្ឋាភិបាល ក្នុងការដឹកនាំសម្របសម្រួលរាល់ធនធាន និងសកម្មភាពរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងអង្គការក្រៅរដ្ឋាភិបាល ព្រមទាំងបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ឲ្យស្របទៅនឹងសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល ស្តីពីការលើកកម្ពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល។

២.៤.៣. សកម្មភាពបោសសម្អាតមីន កំពុងត្រូវបានអនុវត្តដោយកងយោធពលខេមរភូមិន្ទ មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា អង្គការហាឡូត្រាស្ត អង្គការមែក និងអង្គការដោះមីនកម្ពុជា ដែលមានកម្លាំងបោសសម្អាតមីនទាំងអស់ប្រមាណជាង ៥.០០០នាក់ នាពេលបច្ចុប្បន្ន។ លើសពីនេះទៀត កងកម្លាំងនគរបាលជាតិក៏បានចូលរួមក្នុងការតាមដានត្រួតពិនិត្យ និងរាយការណ៍ពីទីតាំង និងស្ថានភាពគំរាមកំហែងដោយសារ ស.ផ.ស.។

២.៤.៤. ភាគីពាក់ព័ន្ធដទៃទៀត ដែលរួមចំណែកក្នុងវិស័យសកម្មភាពមីនមាន ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ[៦] អាជ្ញាធរដែនដី និងអង្គការអភិវឌ្ឍសហគមន៍[៧] និងភ្នាក់ងារអភិវឌ្ឍ ដែលលើកកម្ពស់គម្រោងអភិវឌ្ឍមានលក្ខណៈសមាហរណកម្មជាមួយការដោះមីន[៨]។

២.៤.៥. ដើម្បីធានាឲ្យធនធានបោសសម្អាតមីន ត្រូវបានយកទៅប្រើប្រាស់ចំតំបន់ដែលមានការគំរាមពិតប្រាកដ យន្តការធ្វើផែនការសកម្មភាពមីនថ្មីមួយត្រូវបានបង្កើតឡើង និងដាក់ឲ្យប្រើប្រាស់នៅឆ្នាំ១៩៩៩ ហើយបានជួយសម្របសម្រួលជាមួយសហគមន៍ និងប្រតិបត្តិករដោះមីនក្នុងការកំណត់អាទិភាពផែនការបោសសម្អាតមីនប្រចាំឆ្នាំ[៩]។ ដើម្បីជំរុញការអភិវឌ្ឍនៅក្នុងតំបន់ ដែលរងផលប៉ះពាល់ដោយសារមីន/ស.ផ.ស. គម្រោងសមាហរណកម្មការអភិវឌ្ឍជនបទ ឬសហគមន៍មួយចំនួនត្រូវបានបង្កើតឡើង ហើយបានចាប់ដៃគូជាមួយប្រតិបត្តិករដោះមីន ដើម្បីផ្តល់នូវសេវាបោសសម្អាតមីនទៅតាមសេចក្តីត្រូវការ។ រាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់ផងដែរនូវការចូលរួមពីសំណាក់ប្រជាពលរដ្ឋមូលដ្ឋានក្នុងការប្រែក្លាយដីសង្ស័យ និងដែលមានការគំរាមដោយសារមីន/ស.ផ.ស. ឲ្យទៅជាដីប្រើប្រាស់សម្រាប់បង្កបង្កើនផល[១០] បើទោះបីជាទង្វើទាំងនេះប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ និងមិនត្រូវបានជំរុញលើកទឹកចិត្តឲ្យធ្វើក៏ដោយ។

២.៤.៦. ខណៈពេលដែលកិច្ចខិតខំប្រឹងប្រែងបោសសម្អាតមីនដំបូងបានផ្តោតលើការឆ្លើយតបជាបន្ទាន់ ដើម្បីផ្តល់នូវដីសុវត្ថិភាព និងអាចប្រើប្រាស់បានសម្រាប់ជនភៀសខ្លួនដែលបានវិលត្រឡប់មកពីជំរុំនៅតាមព្រំដែន នោះកិច្ចខិតខំប្រឹងប្រែងបោសសម្អាតមីនទាំងនេះ ត្រូវបានពង្រីកនៅទូទាំងប្រទេសនាចុងទសវត្សរ៍១៩៩០ ហើយការធ្វើសមាហរណកម្មបោសសម្អាតមីន និងការអភិវឌ្ឍក៏ចាប់ផ្តើមកើតឡើងផងដែរ។ ជាមួយនឹងការបង្កើត អ.ធ.ម. នៅឆ្នាំ២០០០ និងការឲ្យប្រើប្រាស់ប្រព័ន្ធចំណាត់អាទិភាពដោយផ្អែកលើតម្រូវការរបស់សហគមន៍មក សកម្មភាពមីនបានក្លាយទៅជាប្រព្រឹត្តកម្មមួយដែលកាន់តែមានលក្ខណៈស៊ីជម្រៅក្នុងកិច្ចគាំទ្រដល់ការកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន/ស.ផ.ស. និងការ

---

៦ AusAid, CIDA, US-DOS, DFID, JICA, GTZ, UNDP, NPA, HI-B, GICHD, JRS, WB, ADB, Japan, Irland, the Netherlands etc.

៧ អាជ្ញាធរខេត្ត ស្រុក ក្រុមប្រឹក្សាឃុំ និងបណ្តាញមូលដ្ឋានអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស.។

៨ សូមមើលគម្រោង ECOSORN ដែលផ្តល់ហិរញ្ញប្បទានដោយ EC គម្រោង ADMAC ដែលផ្តល់ហិរញ្ញប្បទានដោយ CIDA, និងគម្រោង World Vision, Austcare/ Action Aid, CWS, LWF ។

៩ អនុក្រឹត្យលេខ៧០ ស្តីពីការគ្រប់គ្រងកិច្ចប្រតិបត្តិការបោសសម្អាតមីនដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ដែលចែងពីអង្គភាពផែនការសកម្មភាពមីន និងគណៈកម្មាធិការសកម្មភាពមីនខេត្ត ការទទួលខុសត្រូវក្នុងការរៀបចំអាទិភាពចំការមីនដែលត្រូវបោសសម្អាតផ្អែកលើតម្រូវការរបស់សហគមន៍។

10 អ្នកភូមិដោះមីនបានចូលរួមកាត់បន្ថយកម្រិតគ្រោះថ្នាក់លើផ្ទៃដីជាច្រើន ហើយបានប្រែក្លាយដីទាំងនោះសម្រាប់បង្កបង្កើនផល។ សកម្មភាពនេះបាននាំឲ្យរាជរដ្ឋាភិបាលកម្ពុជារៀបចំគោលនយោបាយជាតិ ដូចជាគោលនយោបាយកាត់បន្ថយផ្ទៃដីសង្ស័យដែលអនុញ្ញាតឲ្យប្រតិបត្តិករបោសសម្អាតមីនធ្វើការកាត់បន្ថយផ្ទៃដីសង្ស័យមានមីនពីមុនមក ឲ្យទៅជាដីអាចបង្កបង្កើនផលបាន។

អភិវឌ្ឍសេដ្ឋកិច្ចសង្គម។ កត្តានេះ បានជំរុញឲ្យរាជរដ្ឋាភិបាលកម្ពុជា ដាក់សកម្មភាពមីនបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិចម្បងៗ និងកំណត់ជាគោលដៅទី៩ នៃគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជាផងដែរ។

២.៤.៧. កម្ពុជាក៏បានពង្រីកការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន/ស.ផ.ស. ផងដែរ។ នៅដើមទសវត្សរ៍ ១៩៩០ ការអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស. គឺផ្អែកលើយុទ្ធនាការអប់រំផ្សព្វផ្សាយស្តីអំពីគ្រោះថ្នាក់មីន/ស.ផ.ស. ដល់មហាជន។ លើសពីនេះទៀត ដោយបានរកឃើញថាគ្រោះថ្នាក់ដែលកើតឡើងគឺ បណ្តាលមកពីឥរិយាបថរបស់បុគ្គលដែលមានបញ្ហាជីវភាពនោះ ការតាក់តែងនីតិវិធី និងសារសម្រាប់ការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន/ស.ផ.ស. ក៏បានបង្កើតចេញជាការឆ្លើយតបដែលស្របតាមតម្រូវការរបស់សហគមន៍។

២.៤.៨. កិច្ចសង្គ្រោះជនពិការដោយសារមីន/ស.ផ.ស. ដើមឡើយត្រូវបានដាក់ឲ្យនៅក្រោមការសម្របសម្រួល និងតាមដានត្រួតពិនិត្យរបស់ អ.ធ.ម.។ នៅឆ្នាំ២០០១ ការទទួលខុសត្រូវចំពោះកិច្ចសង្គ្រោះជនរងគ្រោះដោយសារមីន/ស.ផ.ស. ត្រូវបានផ្ទេរជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ក.ស.អ.យ.) និងក្រុមប្រឹក្សាសកម្មភាពជនពិការវិញ។ នៅក្នុងឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តផែនការសកម្មភាពជាតិស្តីពីជនពិការរួមបញ្ចូលជនរងគ្រោះដោយសារមីន/ស.ផ.ស.(ផ.ជ.ស.ជ.) ដែលបង្កើតបានជាក្របខ័ណ្ឌការងាររួមមួយសម្រាប់រៀបចំផែនការ និងកម្មវិធីលម្អិតបន្ថែមទៀត។

## ២.៥. វិធានការអនុវត្ត

### ២.៥.១. ការស្រាវជ្រាវទិន្នន័យមូលដ្ឋាន

ដំណោះស្រាយសម្រាប់រយៈពេល ១០ឆ្នាំខាងមុខ បានផ្តើមចេញពីកិច្ចខិតខំប្រឹងប្រែងថ្មីមួយ ក្នុងការប៉ាន់ប្រមាណទំហំបញ្ហាមីនដែលនៅសល់ឲ្យបានជាក់លាក់។ នៅខែសីហា ឆ្នាំ២០០៩ ការស្រាវជ្រាវទិន្នន័យមូលដ្ឋានបានចាប់ផ្តើមក្នុងគោលបំណងកំណត់នូវតំបន់គំរាមកំហែងដែលនៅសេសសល់ទៅតាមស្តង់ដាចំណាត់ថ្នាក់ដីចំការមីន ហើយលទ្ធផលនៃការស្រាវជ្រាវនេះនឹងត្រូវប្រើជំនួសលទ្ធផលការស្រាវជ្រាវលំដាប់ជាតិកម្រិត១ កន្លងមក។ លទ្ធផលដែលបានមកពីការស្រាវជ្រាវទិន្នន័យមូលដ្ឋាននឹងអាចបំពេញចន្លោះខ្វះខាត ក្នុងប្រព័ន្ធការងាររបស់ក្រុមការងារផែនការសកម្មភាពមីន និងធ្វើឲ្យការរៀបចំផែនការ និងការចាត់អាទិភាពកាន់តែប្រសើរថែមទៀត ដែលនឹងជួយឲ្យការបែងចែកធនធានបោសសម្អាតមីនបានចំគោលដៅដែលមានតម្រូវការខ្ពស់ជាងគេ។ ការស្រាវជ្រាវទិន្នន័យមូលដ្ឋានបានចាប់ផ្តើមជាដំបូងក្នុងស្រុកចំនួន ២១ ដែលមានផលប៉ះពាល់ខ្លាំងជាងគេ ហើយនឹងត្រូវបញ្ចប់នៅដំណាច់ ឆ្នាំ២០១០។ ស្រុកដែលនៅសេសសល់ នឹងត្រូវធ្វើការស្រាវជ្រាវ ក្នុងដំណាក់កាលបន្តបន្ទាប់ ឲ្យបានចប់សព្វគ្រប់ត្រឹមខែធ្នូ ឆ្នាំ២០១២។

### ២.៥.២. ការរំដោះផ្ទៃដីសង្ស័យមានមីន/ស.ផ.ស.

គោលនយោបាយ និងស្តង់ដារំដោះផ្ទៃដីសង្ស័យមានមីនដែលទើបនឹងចេញឲ្យអនុវត្តថ្មីៗនឹងប្រើប្រាស់លទ្ធផលនៃការស្រាវជ្រាវទិន្នន័យមូលដ្ឋាននេះដើម្បីជួយឲ្យ អ.ធ.ម. និងប្រតិបត្តិករបោសសម្អាតមីនអាចឆ្លើយតបប្រកបដោយប្រសិទ្ធភាពថែមទៀតទៅនឹងការគំរាមកំហែងនៅក្នុងតំបន់មានគ្រោះថ្នាក់។ បច្ច័យនេះនឹងបង្កើនប្រសិទ្ធភាព នៃកិច្ចប្រតិបត្តិការបោសសម្អាតមីន ក៏ដូចជាការប្រើប្រាស់ធនធានបោសសម្អាតមីនរឹតតែប្រសើរឡើង។ គោលដៅសំខាន់បំផុតនៃការរំដោះផ្ទៃដីមាន ឬសង្ស័យថាមានមីន/ស.ផ.ស. គឺដើម្បីបង្វែរដីទាំងនោះឲ្យទៅជាដីលែងមានការគំរាមដែលអាចប្រើប្រាស់បានដោយសុវត្ថិភាព។ ការស្រាវជ្រាវទិន្នន័យមូលដ្ឋាន ក៏អាចឲ្យយើងកំណត់បានកាន់តែសុក្រឹត្យថែមទៀតនូវតំបន់ដែលមានការគំរាមពី ស.ផ.ស. ហើយកម្ពុជានឹងធានាឲ្យមាននូវការឆ្លើយតបសមស្របចំពោះការគំរាមដោយសារ ស.ផ.ស. ដែលអនុលោមតាមគោលដៅនៃ ផ.យ.ជ.ម.។

### ២.៥.៣. ការធ្វើផែនការ និងការចាត់អាទិភាព

អ.ធ.ម. បានចាប់ផ្តើមពិនិត្យឡើងវិញ និងធ្វើឲ្យប្រព័ន្ធនៃការរៀបចំផែនការ និងការចាត់អាទិភាពដែលមានស្រាប់កាន់តែប្រសើរជាងមុន ដោយប្រើប្រាស់នូវលទ្ធផលស្រាវជ្រាវទិន្នន័យមូលដ្ឋានដើម្បីធានាឲ្យការបោសសម្អាតមីន ត្រូវបានធ្វើឡើងដោយមានការសម្របសម្រួល រីឯការប្រើប្រាស់ធនធានបោសសម្អាតមីនបានចំភូមិគោលដៅ ដែលនឹងទទួលផលសេដ្ឋកិច្ចសង្គមខ្ពស់ជាងគេបំផុត សំដៅរួមចំណែកជួយដល់ការសម្រេចឲ្យបានតាមគោលដៅនៃ ផ.យ.ជ.ម.។ ប្រព័ន្ធរៀបចំផែនការ និងការចាត់អាទិភាព

ដែលបានកែលម្អថ្មីគួបផ្សំជាមួយនឹងលទ្ធផលនៃការស្រាវជ្រាវទិន្នន័យមូលដ្ឋាននឹងអាចឲ្យកម្ពុជារៀបចំផែនការប្រចាំឆ្នាំ ដែលមានលក្ខណៈគិតគូរពីយេនឌ័រ សំដៅតម្រង់ធនធានឲ្យចំទិសដៅ និងពិនិត្យតាមដានវឌ្ឍនភាពធៀបនឹងគោលដៅជាយុទ្ធសាស្ត្រ។

## ២.៥.៤. ការអភិវឌ្ឍសមត្ថភាព និងការសម្របសម្រួល

វិធានការទាំងនេះនឹងតម្រូវឲ្យភាគីពាក់ព័ន្ធទាំងអស់ចូលរួមសហការ និងតម្រឹមគម្រោង និងកម្មវិធីនានារបស់ខ្លួនឲ្យស្របទៅនឹងអាទិភាពដែលរាជរដ្ឋាភិបាលបានកំណត់។ កិច្ចការនេះតម្រូវឲ្យ អ.ធ.ម. ត្រូវពង្រឹងនូវសមត្ថភាពរបស់ខ្លួនលើការងារសំខាន់ៗមួយចំនួនដូចជា ការរៀបចំផែនការ និងការសម្របសម្រួលសកម្មភាពបោសសម្អាតមីន ការបញ្ជ្រាបយេនឌ័រ ការគ្រប់គ្រងព័ត៌មាន និងការធានាគុណភាព។ វិធានការនេះ ក៏តម្រូវឲ្យមានការរៀបចំ ឬកែសម្រួលឡើងវិញនូវគោលនយោបាយ គោលការណ៍ណែនាំដើម្បីគាំទ្រដល់ដំណើរការការងាររដ្ឋបាលដីធ្លី។ កងយោធពលខេមរភូមិន្ទ បានបង្កើនការចូលរួមរបស់ខ្លួនជាជំហានៗតាមរយៈការដាក់សេចក្តីស្នើសុំអាជ្ញាប័ណ្ណ និងការស្វែងរកធនធានសំដៅពង្រឹងសមត្ថភាពដោះមីនរបស់ខ្លួនថែមទៀត ដើម្បីរួមចំណែកឆ្លើយតបទៅនឹងគោលដៅ ផ.យ.ជ. ម.។

## ២.៥.៥. ស្ថិរភាពក្នុងតំបន់ និងអន្តរជាតិ

កម្ពុជានឹងបន្តរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងរំសាយសព្វាវុធ ដោយធ្វើឲ្យមានការរីកចម្រើនឆ្ពោះទៅសម្រេចឲ្យបាននូវកាតព្វកិច្ចដូចមានចែងក្នុងមាត្រា៥ នៃ អ.ហ.ផ.ម. និងធ្វើរបាយការណ៍ឲ្យបានទៀងទាត់ជូនដល់រដ្ឋភាគី។ កម្ពុជានឹងចូលរួមជាភាគីនៃលិខិតូបករណ៍ ស្តីពីការរំសាយសព្វាវុធមួយចំនួនទៀតឲ្យបានឆាប់ ដូចជាពិធីសារទី៥ ស្តីពី ស.ផ.ស. នៃអនុសញ្ញាសព្វាវុធធម្មតាមួយចំនួន ដែលអាចបង្កមហន្តរាយធំធេង ឬបង្កផលប៉ះពាល់ដោយមិនរើសមុខ ដើម្បីជាការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងការពារសន្តិភាព និងសន្តិសុខលើពិភពលោក ហើយកម្ពុជានឹងធ្វើកិច្ចសហប្រតិបត្តិការឲ្យកាន់តែជិតស្និទ្ធជាមួយប្រទេសជិតខាង ដើម្បីបោសសម្អាតមីន/ស.ផ.ស. សំដៅគាំទ្រដល់ការងារបោះបង្គោលព្រំដែន។

## ២.៥.៦. ការអប់រំកាត់បន្ថយគ្រោះថ្នាក់ និងកិច្ចជួយសង្គ្រោះជនរងគ្រោះ

ការអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស. នៅតែជាសមាសភាគដ៏សំខាន់ដើម្បីសម្រេចឲ្យបាននូវគោលដៅនៃ ផ.យ.ជ.ម. ក្នុងការកាត់បន្ថយករណីគ្រោះថ្នាក់ និងផលប៉ះពាល់អវិជ្ជមានដោយសារមីន/ស.ផ.ស. នៅសហគមន៍មូលដ្ឋាន។ ភាគីពាក់ព័ន្ធទាំងអស់ត្រូវបន្តការរៀបចំសកម្មភាព និងសារអប់រំដោយផ្តោតទៅលើឥរិយាបថគ្រោះថ្នាក់សម្រាប់ក្រុមជនដែលនៅងាយរងគ្រោះទាំងពីរភេទ។ វិស័យសកម្មភាពមីនក៏ត្រូវកំណត់ឡើងវិញនូវយន្តការអនុវត្តការងារអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស. ដោយបង្កើនការប្រើប្រាស់បណ្តាញស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ បើទោះបីជា សេវាជួយជនរងគ្រោះដោយសារមីន/ស.ផ.ស. ត្រូវបានបញ្ចូលទៅក្នុងផែនការសកម្មភាពជាតិ ស្តីពីជនពិការក៏ដោយក៏ភាគីពាក់ព័ន្ធក្នុងសកម្មភាពមីននៅបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចគាំទ្រដល់ ក.ស.អ.យ. និងបណ្តាសហគមន៍ជួយសង្គ្រោះជនពិការតាមរយៈការពង្រឹងការប្រមូលទិន្នន័យការតស៊ូមតិ និងកិច្ចខិតខំកៀរគរធនធានសម្រាប់សេវាជួយជនរងគ្រោះ ឲ្យស្របតាមតម្រូវការជាក់ស្តែង។

## ២.៥.៧. និរន្តរភាពសមត្ថភាព

កម្ពុជាមានគោលបំណងចាកឲ្យផុតពីការគំរាមកំហែងដោយសារមីនប្រឆាំងមនុស្សក្នុងរយៈពេល ១០ឆ្នាំទៀត។ ដើម្បីឆ្លើយតបនូវតម្រូវការរយៈពេលវែងក្នុងការដោះស្រាយបញ្ហាមីនដែលនៅសេសសល់ និង ស.ផ.ស. គឺទាមទារឲ្យមាននិរន្តរភាពសមត្ថភាពជាតិ។ ជាដំបូង អ.ធ.ម. ត្រូវពង្រឹងសមត្ថភាពបន្ថែមទៀត។ ការសិក្សាវាយតម្លៃសមត្ថភាពនឹងជួយត្រួសត្រាយផ្លូវដើម្បីបង្កើនសមត្ថភាពឆ្ពោះទៅសម្រេចបេសកកម្មរបស់ខ្លួន។ រាជរដ្ឋាភិបាលកម្ពុជានឹងសម្របសម្រួលកិច្ចពិភាក្សាក្នុងចំណោមអ្នកទទួលខុសត្រូវថ្នាក់ជាតិសំខាន់ៗដូចជា កងយោធពលខេមរភូមិន្ទ មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា និងកងកម្លាំងនគរបាលជាតិដើម្បីពិនិត្យឡើងវិញនូវក្របខ័ណ្ឌការងារស្ថាប័ន និងកំណត់គម្លាតសមត្ថភាពការងារដែលត្រូវដោះស្រាយបំពេញដើម្បីធានាឲ្យមានស្ថាប័នសមស្រប និងមានចីរភាពក្នុងការដោះស្រាយបញ្ហាមីន/ស.ផ.ស. ដែលនៅសេសសល់។

# ជំពូកទី ៣
# តម្រូវការធនធាន

១. រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា ភាពជាដៃគូបានធ្វើឲ្យសម្រេចនូវសមិទ្ធផលសំខាន់ៗជាច្រើនក្នុងរយៈពេលជាង ១៨ ឆ្នាំកន្លងមកនេះ សម្រាប់វិស័យសកម្មភាពមីន។ ការចូលរួមយ៉ាងសកម្មពីដៃគូអភិវឌ្ឍទាំងអស់ ជាពិសេសប្រតិបត្តិករបោសសម្អាតមីននឹងដើរតួនាទីសំខាន់ក្នុងការធ្វើឲ្យសម្រេចគោលដៅនៃ ផ.យ.ជ.ម.។ កម្ពុជាបានទទួលផលប្រយោជន៍យ៉ាងច្រើនពីការរួមចំណែកដ៏សំខាន់មិនដែលដាច់ពីសហគមន៍អន្តរជាតិដែលបានផ្តល់ថវិកាគាំទ្រសកម្មភាពមីនតាំងពីឆ្នាំ១៩៩២ មក ដែលបានទទួលប្រមាណ ២៩ លានដុល្លារក្នុងមួយឆ្នាំៗ ដែលបានចូលរួមជួយសង្គ្រោះអាយុជីវិតប្រជាជនកម្ពុជាឲ្យរួចផុតពីការគំរាមកំហែង និងជួយគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា បានយ៉ាងច្រើនគួរឲ្យកត់សម្គាល់។

២. រាជរដ្ឋាភិបាលកម្ពុជាបានរួមចំណែកផ្តល់ថវិកាដល់ស្ថាប័នជាតិពាក់ព័ន្ធនឹងសកម្មភាពមីន ដែលមានចំនួនកើនឡើងជារៀងរាល់ឆ្នាំ (គឺ ៣,៣២ លានដុល្លារ ក្នុងឆ្នាំ២០០៩) ហើយថវិកាមួយចំនួនធំត្រូវបានវិស័យសាធារណៈ និងឯកជនវិនិយោគសម្រាប់ការដោះមីនដើម្បីគាំទ្រដល់កិច្ចអភិវឌ្ឍ និងការស្តាបនាហេដ្ឋារចនាសម្ព័ន្ធឡើងវិញ។ រាជរដ្ឋាភិបាលនឹងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន និងប្តេជ្ញាធ្វើឲ្យសម្រេចតាមគោលដៅទាំងឡាយនៃយុទ្ធសាស្ត្រនេះ និងស្វាគមន៍ភាពជាដៃគូទាំងផ្នែកឯកជន និងសាធារណៈឯកជនសម្រាប់ការបោសសម្អាតមីនក្នុងកិច្ចគាំទ្រដល់កំណើនសេដ្ឋកិច្ច។

៣. យោងតាមអាណត្តិ ១០ឆ្នាំថ្មី នៃការអនុវត្តតាមមាត្រា៥ នៃ អ.ហ.ផ.ម. ដែលមានចែងត្រង់ចំណុច ២ នៃជំពូក១ កម្ពុជាត្រូវធ្វើការបោសសម្អាតមីនប្រឆាំងមនុស្សទាំងស្រុងលើផ្ទៃដី ៦៤៨,៨ គ.ម២ និងផ្ទៃដីសង្ស័យថាមានមីន ១.០៩៧,៨ គ.ម២ ដែលចាំបាច់ត្រូវធ្វើការរំដោះតាមរយៈការស្រាវជ្រាវទិន្នន័យមូលដ្ឋាន និងការស្រាវជ្រាវបច្ចេកទេស។ ដើម្បីសម្រេចផែនការនេះ កម្ពុជាត្រូវការថវិកាចំនួនប្រមាណ ៤៥៥ លានដុល្លារ។

៤. ដូចមានចែងត្រង់ចំណុច ៣ នៃជំពូក១ ការគំរាមកំហែងដោយសារ ស.ផ.ស. បានបង្កគ្រោះថ្នាក់ដល់អាយុជីវិតប្រជាពលរដ្ឋ និងជាឧបសគ្គក្នុងការអភិវឌ្ឍសង្គមយ៉ាងធ្ងន់ធ្ងរ។ ដោយផ្អែកលើតម្រូវការបន្ទាន់ចំពោះមុខ កម្ពុជាចាំបាច់ត្រូវដោះស្រាយបញ្ហា ស.ផ.ស. យ៉ាងហោចណាស់ឲ្យបានប្រមាណ ១០០ គ.ម២ ក្នុងមួយឆ្នាំៗ។ ដើម្បីគាំទ្រឲ្យសម្រេចផែនការនេះបាន កម្ពុជាត្រូវការថវិកាប្រចាំឆ្នាំជាង ១២ លានដុល្លារ បន្ថែមទៀត។

៥. លើសពីនេះទៀត កម្រិតថវិកាសម្រាប់គាំទ្រសកម្មភាពអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស. ក្នុងចំនួនប្រមាណ ០,៦ លានដុល្លារក្នុងមួយឆ្នាំ ត្រូវតែបង្កើនថែមទៀតដើម្បីសម្រេចនូវគោលដៅនៃការអប់រំកាត់បន្ថយគ្រោះថ្នាក់ ដូចមានចែងនៅក្នុងយុទ្ធសាស្ត្រ។ ខណៈដែលវិស័យសកម្មភាពមីននឹងបន្តជួយកៀរគរធនធានឲ្យកាន់តែច្រើនបន្ថែមទៀតជាពិសេសសម្រាប់ជនរងគ្រោះដោយសារមីន/ស.ផ.ស. តាមរយៈការអនុវត្ត ផ.ជ.ស.ជ. ការឧបត្ថម្ភគាំទ្រកិច្ចសង្គ្រោះជនរងគ្រោះដោយសារមីន/ស.ផ.ស. គួរតែត្រូវបានបង្កើនឡើងក្នុងកញ្ចប់ជំនួយសម្រាប់វិស័យពិការភាព។ ការគាំទ្រដល់គោលនយោបាយជាតិ ការរៀបចំផែនការ និងមុខងារសម្របសម្រួលក៏ត្រូវតែបង្កើនឡើងដើម្បីសម្របសម្រួលដល់ការអនុវត្ត និងការតាមដានត្រួតពិនិត្យនូវយុទ្ធសាស្ត្រឲ្យស្របគ្នា ជាមួយការកែទម្រង់ស្ថាប័ន និងរចនាសម្ព័ន្ធចាត់តាំងក៏ដូចជាបន្តពង្រឹង និងរក្សាសមត្ថភាពរបស់ អ.ធ.ម. ក្នុងកម្រិតមួយដែលអាចផ្តល់នូវសេវាដែលមានគុណភាព និងសមស្របសម្រាប់វិស័យសកម្មភាពមីន។

៦. តារាងតម្រូវការថវិកាតាមឆ្នាំដែលត្រូវវិភាជន៍ពីឆ្នាំ ២០១០-២០១៩ សម្រាប់ការស្រាវជ្រាវទិន្នន័យមូលដ្ឋាន និងការបោសសម្អាតមីន គឺមានចែងនៅក្នុងឧបសម្ព័ន្ធ ខ។

៧. កម្ពុជាជឿជាក់ថា ការអនុវត្តផែនការសកម្មភាពសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល និងសូចនាករតាមដានរួមគ្នាដោយភាគីពាក់ព័ន្ធទាំងអស់ គឺជាកត្តាសំខាន់ក្នុងការអនុវត្ត ផ.យ.ជ.ម. ឲ្យបានជោគជ័យ។ ការងារនេះ តម្រូវឲ្យដៃគូអភិវឌ្ឍទាំងអស់សម្របសម្រួល និងតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការរបស់ខ្លួនដោយរៀបចំគម្រោង និងកម្មវិធីរបស់ខ្លួនឲ្យគាំទ្រដល់គោលដៅទាំងឡាយនៃយុទ្ធសាស្ត្រ និងផែនការការងារប្រចាំឆ្នាំ។ បញ្ហាធំមួយក្នុងចំណោមបញ្ហាប្រឈមជាច្រើន គឺការលើកកម្ពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការក្នុងវិស័យសកម្មភាពមីន ដែលទាក់ទងទៅនឹងការគ្រប់គ្រងព័ត៌មានដែលដៃគូអនុវត្តគម្រោងសកម្មភាពមីនទាំងអស់ត្រូវរាយការណ៍មក អ.ធ.ម. នូវលទ្ធផលសកម្មភាពបញ្ហាប្រឈម និងការប្រើប្រាស់ធនធានធៀបនឹងផែនការការងារប្រចាំឆ្នាំរបស់ខ្លួន។ ព័ត៌មានស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការត្រូវផ្តល់ជូនរាជរដ្ឋាភិបាល ដើម្បីដាក់បញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍផ្លូវការនៅកម្ពុជានិងរបស់អ.ធ.ម.។ទាំងរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍនឹងរាយការណ៍អំពីការរួមចំណែករបស់ខ្លួនក្នុងវិស័យសកម្មភាពមីនឲ្យមានតម្លាភាព និងតាមពេលកំណត់។

៨. ក្រុមការងារបច្ចេកទេសចម្រុះសកម្មភាពមីននឹងខិតខំធ្វើឲ្យប្រសើរឡើងថែមទៀតលើការងារសម្របសម្រួល ការបង្ហាញនូវតម្លាភាព និងការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការ ព្រមទាំងផ្តល់ជាវេទិកាសម្រាប់ការសម្របសម្រួលគម្រោងកម្មវិធី និងការតាមដានត្រួតពិនិត្យលទ្ធផល នៃការអនុវត្ត ផ.យ.ជ.ម. ។

# ជំពូកទី ៤

# ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

១. អ.ធ.ម. នឹងរៀបចំផែនការការងារប្រចាំឆ្នាំដោយមានការពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍ ដើម្បីយកយុទ្ធសាស្ត្រនេះមកប្រតិបត្តិជាក់ស្តែង។ ផែនការនោះនឹងមានកំណត់នូវចំណុចដៅ និងសកម្មភាពការងារមួយចំនួនដែលត្រូវឆ្លើយតបទៅនឹងគោលដៅ និងសូចនាករទាំងឡាយដែលមានចែងក្នុង ផ.យ.ជ.ម.។ យន្តការសម្រាប់ប្រមូល និងវិភាគទិន្នន័យដើម្បីតាមដាននូវសមិទ្ធផល និងវឌ្ឍនភាពដែលសម្រេចបានក្នុងការអនុវត្តសកម្មភាពការងារទាំងនោះនឹងត្រូវបានលើកកម្ពស់ រីឯវិធីសាស្ត្រដើម្បីវាស់វែងសមិទ្ធផលទាំងនោះធៀបនឹងគោលដៅរបស់យុទ្ធសាស្ត្រជាពិសេសគឺសូចនាករសម្រាប់តាមដានការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រនឹងត្រូវរៀបចំឡើង។

២. ផ.យ.ជ.ម. គឺជាឯកសាររស់ដែលត្រូវតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងកែលម្អឡើងវិញដើម្បីឲ្យយុទ្ធសាស្ត្រនេះអាចបំពេញតួនាទីជាឯកសារយោង និងជាឧបករណ៍បង្ហាញផ្លូវដល់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងវិស័យសកម្មភាពមីន។ ការវាយតម្លៃលើកទី១ នឹងត្រូវធ្វើឡើងនៅក្នុងឆ្នាំ ២០១៣ ហើយការកែសម្រួល ផ.យ.ជ.ម. នឹងត្រូវយកមកប្រើប្រាស់ជាធាតុចូលសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបន្ទាប់ ២០១៤-២០១៨។ ការត្រួតពិនិត្យវាយតម្លៃឡើងវិញចុងក្រោយនឹងត្រូវធ្វើឡើងនៅក្នុងឆ្នាំ២០១៩។

# សេចក្ដីសន្និដ្ឋាន

១. ផ.យ.ជ.ម. ត្រូវបានរៀបចំឡើងនៅឆ្នាំ២០០៩ ក្រោមការដឹកនាំសម្របសម្រួលដោយ អ.ធ.ម. តាមរយៈដំណើរការពិគ្រោះពិភាក្សាគ្រប់ជ្រុងជ្រោយជាមួយភាគីពាក់ព័ន្ធនឹងសកម្មភាពមីនទាំងអស់នៅកម្ពុជា។

២. ឯកសារ ផ.យ.ជ.ម. គឺជាឯកសារមួយប្រមើលមើលពីអនាគត នៃវិស័យសកម្មភាពមីន ដែលមានគោលដៅប្រកបដោយមហិច្ឆតា និងឆ្លុះបញ្ចាំងពីឆន្ទៈ ក្នុងការប្រែក្លាយកម្ពុជាឲ្យទៅជាប្រទេសមួយ ដែលប្រជាពលរដ្ឋគ្រប់រូប បុរស ស្ត្រី និងកុមារ អាចរស់នៅចាកផុតពីការគំរាមកំហែងទាំងស្រុង ដោយសារមីនប្រឆាំងមនុស្ស និងកាត់បន្ថយការគំរាមកំហែងដោយសារមីនប្រឆាំងរថក្រោះ និង ស.ផ.ស. ឲ្យបានជាអតិបរមា ហើយដែលញ៉ាំងឲ្យការអភិវឌ្ឍលើគ្រប់វិស័យ អាចប្រព្រឹត្តទៅក្នុងបរិយាកាស ប្រកបដោយសុវត្ថិភាព។ លើសពីនេះ ផ.យ.ជ.ម. ក៏បានលើកកម្ពស់សិទ្ធិជនរងគ្រោះ ដោយសារមីន/ស.ផ.ស. និងសហគមន៍ដែលរងផលប៉ះពាល់ផងដែរ។

៣. ផ.យ.ជ.ម. ត្រូវបានរៀបចំឡើងដែលមានចក្ខុវិស័យអាចឲ្យកម្ពុជាអនុវត្តបានពេញលេញនូវកាតព្វកិច្ចរបស់ខ្លួនដែលជារដ្ឋភាគីនៃអនុសញ្ញា អ.ហ.ផ.ម. ហើយគាំទ្រយ៉ាងមុតមាំនូវចំណុចដៅដែលមានចែងនៅក្នុងសេចក្ដីស្នើសុំពន្យារពេលរបស់ខ្លួនស្របតាមមាត្រា៥ ដែលទទួលបានការឯកភាពដោយសន្និសីទកំពូលពិនិត្យឡើងវិញលើកទី២ នៃអនុសញ្ញា អ.ហ.ផ.ម. នៅក្រុងកាតាហេណា ប្រទេសកូឡុំប៊ី កាលពីខែធ្នូ ឆ្នាំ២០០៩។

៤. ផ.យ.ជ.ម. គឺជាក្របខ័ណ្ឌយុទ្ធសាស្ត្រថ្មីមួយសម្រាប់សកម្មភាពមីននៅកម្ពុជា ដែលអាចគ្របដណ្ដប់រាល់ការអនុវត្តគម្រោង និងកម្មវិធីពាក់ព័ន្ធទាំងអស់។ ការអនុវត្តយុទ្ធសាស្ត្រនេះនឹងតម្រូវឲ្យមានការគាំទ្រឲ្យបានខ្លាំង និងជានិរន្តរ៍ទាំងពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា សប្បុរសជន និងដៃគូអភិវឌ្ឍ។ ដូចនេះ កម្ពុជាត្រូវលើកកម្ពស់ ការតម្រឹម និងសុខដុមនីយកម្មរវាងយុទ្ធសាស្ត្រទាំងឡាយ របស់ដៃគូអភិវឌ្ឍពាក់ព័ន្ធនឹងសកម្មភាពមីន ឲ្យស៊ីសង្វាក់គ្នានឹងគោលដៅរបស់ ផ.យ.ជ.ម.។ កម្ពុជាក៏បានអនុវត្តសកម្មភាពមួយចំនួនជាបណ្ដើរៗ ហើយដែរក្នុងការពង្រឹងសមត្ថភាពរបស់ខ្លួនលើគ្រប់ទិដ្ឋភាពទាក់ទងការងារសម្របសម្រួលការធ្វើនិយតកម្ម និងការតាមដានត្រួតពិនិត្យ ដើម្បីធានាឲ្យសកម្មភាពពាក់ព័ន្ធនឹងវិស័យមីនទាំងអស់ត្រូវបានដាក់ឲ្យចំគោលដៅមានប្រសិទ្ធភាព និងប្រសិទ្ធផល។

៥. កម្ពុជា សូមសំដែងនូវអំណរគុណដ៏ជ្រាលជ្រៅចំពោះការឧបត្ថម្ភគាំទ្រសម្រាប់កម្មវិធីសកម្មភាពមីនរយៈពេលជិតពីរទសវត្សរ៍កន្លងមក និងមានមោទនភាពដោយត្រូវបានចាត់ជាគំរូក្នុងការចែករំលែកបទពិសោធខាងវិស័យមីនជាមួយប្រទេសដទៃៗទៀត។ កម្ពុជា ត្រៀមខ្លួនជានិច្ចដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្ត ផ.យ.ជ.ម. ២០១០-២០១៩។

# ឧបសម្ព័ន្ធ ក : តារាងសូចនាករ និងចំណុចដៅ

## គោលដៅទី១: កាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស. និងផលប៉ះពាល់អវិជ្ជមានដទៃទៀត

| គោលដៅ | សូចនាករ | ឯកតា | ទិន្នន័យមូលដ្ឋាន | ចំណុចដៅ | | | | សកម្មភាព |
|---|---|---|---|---|---|---|---|---|
| | | | ២០០៩ | ២០១០ | ២០១២ | ២០១៥ | ២០១៩ | |
| ១.១. វិភាជន៍ធនធានបោសសម្អាតមីនដល់កន្លែងដែលរងផលប៉ះពាល់ខ្លាំង | ការវិភាជន៍ធនធាន: អត្រាភាគរយនៃការវិភាជធនធានបោសសម្អាតមីន សំរាប់គាំទ្រដល់ផែនការសកម្មភាព | % | ៤៤ | ៥០ | ៨០ | ៩០ | ៩០ | ពង្រឹងការធ្វើផែនការបោសសម្អាតមីនថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងយន្តការសម្របសម្រួល |
| | អត្រាភាគរយសំណើសុំបោសសម្អាតមីនបន្ទាន់ធៀបនឹងផែនការសកម្មភាពប្រចាំឆ្នាំ | % | ៥៦ | ៥០ | ២០ | ១០ | ១០ | |
| | ចំនួនជនរងគ្រោះដោយសារមីន/ស.ផ.ស. (ស្លាប់និងរបួស) | នាក់ | ២៤៤ | <២៥០ | <២០០ | <១៥០ | <១០០ | |
| | ចំនួនស្រុកបញ្ចប់ការស្រាវជ្រាវទិន្នន័យមូលដ្ឋាន | ចំនួន | ០ | ២១ | ១២២ | | | បញ្ចប់ការងារស្រាវជ្រាវទិន្នន័យមូលដ្ឋាន |
| | ការកៀរគរធនធាន: អត្រាភាគរយនៃធនធានបោសសម្អាតមីនទទួលបាន ធៀបនឹងធនធានដែលត្រូវការ | % | ៨១ | ៨៤ | ៩០ | ១០០ | ១០០ | កៀរគរធនធានបោសសម្អាតមីនដើម្បីគាំទ្រផែនការបោសសម្អាតមីន/ស.ផ.ស. ប្រចាំឆ្នាំ |
| | ផ្ទៃដីសប្របោសសម្អាតមីន/ ស.ផ.ស[១១] | ហត | ៥២,៩១៨ | ៥៨,២៩២ | ៦៩,៣៦៣ | ៨៦,៨១៣ | ១១១,៧៥៤ | អនុវត្តផែនការបោសសម្អាតមីន/ស.ផ.ស. ប្រចាំឆ្នាំ |
| | ប្រព័ន្ធគ្រប់គ្រងព័ត៌មានត្រូវបានកែលម្អ និងឆ្លើយតបទៅនឹងតម្រូវការ | អត្ថបទ | ប្រព័ន្ធព័ត៌មានកម្រិតមូលដ្ឋាន | ប្រព័ន្ធព័ត៌មានកម្រិតមូលដ្ឋាន | ប្រព័ន្ធគ្រប់គ្រងព័ត៌មានដំណើរការ | ប្រព័ន្ធព័ត៌មានមាននិរន្តរភាព | ប្រព័ន្ធព័ត៌មានមាននិរន្តរភាព | ពង្រឹង និងថែរក្សាប្រព័ន្ធគ្រប់គ្រងព័ត៌មានមីន/ស.ផ.ស. ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ |
| ១.២. ផ្តល់ការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន/ស.ផ.ស. ប្រកបដោយប្រសិទ្ធភាព | អត្រាភាគរយនៃសកម្មភាពអប់រំកាត់បន្ថយគ្រោះថ្នាក់ដែលអនុវត្តនៅកន្លែងដែលរងផលប៉ះពាល់ខ្លាំង | | % | NA | ៧០ | ៨០ | ៩០ | ពង្រឹងការផ្តល់សេវាអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ ស.ផ.ស. សម្រាប់ក្រុមគោលដៅដែលងាយរងគ្រោះបំផុត |
| | ការអនុវត្តផែនការអប់រំកាត់បន្ថយគ្រោះថ្នាក់: ភាគរយនៃលទ្ធផលសម្រេចបានធៀបនឹងផែនការប្រចាំឆ្នាំ | % | NA | ៧០ | ៨០ | ៩០ | ១០០ | ពិនិត្យឡើងវិញនូវក្របខ័ណ្ឌការងារនៃស្ថាប័នសម្រាប់បណ្តាញអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស. |
| | អត្រាភាគរយនៃបុរស ស្ត្រី និងកុមារនៅក្នុងភូមិដែលរងនូវផលប៉ះពាល់ បានយល់ដឹងពីការអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស. | % | NA | ៧០ | ៨០ | ៩០ | ១០០ | ក្សានិរន្តរភាពការងារអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ ស.ផ.ស. ក្នុងកម្មវិធីសិក្សានៅតាមបណ្តាខេត្តដែលទទួលរងផលប៉ះពាល់ដោយសារមីន/ស.ផ.ស. |

[១១] អត្រាកំណើននៃផ្ទៃដីបោសសម្អាតមីនចំនួនប្រហែល ២% ក្នុងមួយឆ្នាំ គិតរយៈពេលបីឆ្នាំចុងក្រោយ។ តាមការព្យាករណ៍កំណើននៃការបោសសម្អាតមីនមានប្រហែល ២% ឬច្រើនជាងនេះផ្អែកតាមថវិកា និងការអភិវឌ្ឍបច្ចេកទេសក្នុងរយៈពេល ១០ឆ្នាំខាងមុខ។

## គោលដៅទី២: រួមចំណែកដល់ការជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ

| គោលដៅ | សូចនាករ | ឯកតា | ទិន្នន័យមូលដ្ឋាន | ចំណុចដៅ | | | | សកម្មភាព |
|---|---|---|---|---|---|---|---|---|
| | | | ២០០៩ | ២០១០ | ២០១២ | ២០១៥ | ២០១៩ | |
| ២.១. គាំទ្រដល់អាទិភាពអភិវឌ្ឍសហគមន៍ដែលរងផលប៉ះពាល់ដោយសារមីន/ស.ផ.ស. | អត្រាភាគរយនៃធនធានសំរាប់វិស័យសកម្មភាពមីនប្រចាំឆ្នាំ ដែលទទួលបានពីថវិកាជាតិ | % | ១០ | ៨ | ១៣ | ២០ | ៣០ | ពង្រឹងការធ្វើផែនការបោសសម្អាតមីនថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងយន្តការសម្របសម្រួល |
| | អត្រាភាគរយនៃសំណើសុំបន្ទាន់ជៀបនឹងផែនការបោសសម្អាតមីនប្រចាំឆ្នាំ[១២] | % | ៥៦ | ៥០ | ២០ | ១០ | ១០ | |
| | ចំនួនស្រុកបញ្ចប់ការស្រាវជ្រាវទិន្នន័យមូលដ្ឋាន[១៣] | ចំនួន | ០ | ២១ | ១២២ | | | |
| | ផ្ទៃដីសរុបដែលបានបោសសម្អាតមីន/ស.ផ.ស[១៤] | ហត | ៥២,៩១៨ | ៥៨,២៩២ | ៦៩,៣៦៣ | ៨៦,៨១៣ | ១១១,៧៥៤ | បញ្ចប់ការងារស្រាវជ្រាវទិន្នន័យមូលដ្ឋាន |
| | ការកៀរគរធនធាន: អត្រាភាគរយនៃធនធានបោសសម្អាតមីនទទួលបានជៀបនឹងធនធានដែលត្រូវការ | % | ៨១ | ៨៤ | ៩០ | ១០០ | ១០០ | កៀរគរធនធានបោសសម្អាតមីនដើម្បីគាំទ្រផែនការបោសសម្អាតមីន/ស.ផ.ស. ប្រចាំឆ្នាំ |
| | ការតាមដានត្រួតពិនិត្យ: ភាគរយនៃផ្ទៃដីដោះមីនរួចមិនបានប្រើប្រាស់ដែលបានរកឃើញនៅពេលចុះតាមដានត្រួតពិនិត្យ | % | ៦ | ៥ | ៤ | ២ | ០ | អនុវត្តផែនការបោសសម្អាតមីន/ស.ផ.ស. ប្រចាំឆ្នាំ |
| | ការវាយតម្លៃ: ការរួមចំណែកនៃការបោសសម្អាតមីនក្នុងការកាត់បន្ថយភាពក្រីក្រ | | សូចនាករ និងចំណុចដៅនឹងត្រូវកំណត់នៅពេលក្រោយ | | | | | |
| | ការទទួលខុសត្រូវថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការអនុវត្ត ការតាមដានត្រួតពិនិត្យការបោសសម្អាតមីនដែលបានកំណត់ និងបញ្ចូលក្នុងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ | អត្ថបទ | សិក្សាពីលទ្ធភាព បញ្ហា ប | បញ្ជ្រាបផែនការសកម្មភាពមីនជាមួយផែនការថ្នាក់ក្រោមជាតិ | សមាហរណកម្មផែនការសកម្មភាពមីនជាមួយផែនការថ្នាក់ក្រោមជាតិ | និរន្តរភាព | និរន្តរភាព | ជួយនិងគាំទ្រគំនិតផ្តួចផ្តើមថ្មីៗ សម្រាប់ដំណើរការរៀបចំផែនការតាមបែបវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល |

[១១] សូចនាករ និង ចំណុចដៅគាំទ្រដល់ ១.១. ផងដែរ
[១២] សូចនាករ និង ចំណុចដៅគាំទ្រដល់ ១.១. ផងដែរ
[១៣] សូចនាករ និង ចំណុចដៅគាំទ្រដល់ ១.១. ផងដែរ

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២.២. គាំទ្រដល់ការអភិវឌ្ឍជាអាទិភាព ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ការអនុវត្ត: អត្រាភាគរយនៃលទ្ធផលសម្រេចបានធៀបនឹងផែនការប្រចាំឆ្នាំ | % | ៤៤ | ៥០ | ១០០ | ១០០ | ១០០ | ពង្រឹងការផ្តល់សេវាអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ ស.ផ.ស. សម្រាប់ក្រុមគោលដៅដែលងាយរងគ្រោះបំផុត |
| | ការកៀរគរថវិកា: អត្រាភាគរយនៃធនធានសំរាប់វិស័យសកម្មភាពមីនប្រចាំឆ្នាំ ដែលទទួលបានពីថវិកាជាតិ | % | ១០ | ៨ | ១៣ | ២០ | ៣០ | ពិនិត្យឡើងវិញនូវក្របខ័ណ្ឌការងារនៃស្ថាប័នសម្រាប់បណ្តាញអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស. |
| ២.៣. គាំទ្រដល់ជនរងគ្រោះដោយសារមីន /ស.ផ.ស. និងគ្រួសាររបស់ពួកគេឲ្យទទួលបានការថែទាំសុខភាព និងការស្តា រលទ្ធភាពពលកម្ម និងគាំទ្រសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ | ការផ្តល់សេវាកម្ម: អត្រាភាគរយនៃជនពិការដោយសារមីន/ស.ផ.ស. បានទទួលសេវាគាំទ្រ។ | % | ៧៦ | ៨៣ | ៩០ | ៩០ | ៩០ | គាំទ្រផែនការសកម្មភាពជាតិស្តីពីជនពិការរួមបញ្ចូលជនរងគ្រោះដោយសារមីន/ស.ផ.ស. |
| | ការបញ្ចូលទិន្នន័យប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន/ស.ផ.ស. កម្ពុជា ដែលមានញែកតាមភេទទៅក្នុងប្រព័ន្ធទិន្នន័យសកម្មភាពមីនថ្នាក់ជាតិ | អត្ថបទ | អនុវត្ត | អនុវត្ត | និរន្តរភាព | និរន្តរភាព | និរន្តរភាព | បញ្ចូលទិន្នន័យប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន/ ស.ផ.ស. កម្ពុជា ទៅក្នុងប្រព័ន្ធទិន្នន័យសកម្មភាពមីនថ្នាក់ជាតិ |
| ២.៤. គាំទ្រដល់ដំណើរការរដ្ឋបាលដីធ្លី ដើម្បីធានាសិទ្ធិប្រើប្រាស់ដីស្របច្បាប់ជូនអ្នកដែលត្រូវទទួលផលលើដីបោសសម្អាតមីនរួច | អត្រាភាគរយនៃផ្ទៃដីបោសសម្អាតមីនរួចដែលអាចនឹងមានទំនាស់ក្នុងការប្រើប្រាស់ដី | % | ៦ | ៥ | ៣ | ០ | ០ | គាំទ្រគំនិតផ្តួចផ្តើម ក្នុងការដោះស្រាយបញ្ហារដ្ឋបាលដីធ្លី |
| | នីតិវិធីទាំងឡាយនឹងត្រូវបង្កើតឡើង ដើម្បីធានាឲ្យមានភាពស្របគ្នាទៅនឹងគោលនយោបាយដីធ្លី | អត្ថបទ | សិក្សាពីលទ្ធភាពផ្តល់ទិន្នន័យ | សិក្សាពីចំណាត់ថ្នាក់ដីចំការមីន | ផ្តល់ទិន្នន័យដីដោះមីន | បន្តផ្តល់ទិន្នន័យ | បន្តផ្តល់ទិន្នន័យ | ផ្តល់ទិន្នន័យ និងព័ត៌មានពាក់ព័ន្ធនឹងសកម្មភាពមីនជូនក្រសួងស្ថាប័នមានសមត្ថកិច្ច ដើម្បីគាំទ្រដល់ការបែងចែកដីដោះមីនរួចជូនអ្នកទទួលផល |

## គោលដៅទី៣: ធានានូវនិរន្តរភាពសមត្ថភាពជាតិក្នុងការដោះស្រាយបញ្ហាមីន/ស.ផ.ស. ដែលនៅសេសសល់

| គោលដៅ | សូចនាករ | ឯកតា | ទិន្នន័យមូលដ្ឋាន | | | | | សកម្មភាព |
|---|---|---|---|---|---|---|---|---|
| | | | ២០០៩ | ២០១០ | ២០១២ | ២០១៥ | ២០១៩ | |
| ៣.១. ពិនិត្យឡើងវិញ នូវក្របខ័ណ្ឌស្ថាប័នសម្រាប់ដោះស្រាយបញ្ហាមីន/ស.ផ.ស. ដែលនៅសេសសល់[១៩] | កំណត់កម្រិតនៃការគំរាមពីមីន/ស.ផ.ស. ដែលនៅសេសសល់ឲ្យបានត្រឹមឆ្នាំ២០១៣ | | | | ចាប់ផ្ដើម (២០១៣) | | | កំណត់តម្រូវការដើម្បីដោះស្រាយការគំរាមពី មីន/ស.ផ.ស. ដែលនៅសេសសល់ |
| | តម្រូវការសមត្ថភាព ក្នុងការដោះស្រាយបញ្ហាមីន/ស.ផ.ស. ដែលនៅសេសសល់ ត្រូវបានវាយតម្លៃ | | | | ចាប់ផ្ដើម (២០១៣) | | | |
| | ផ.យ.ជ.ម. ដើម្បីដោះស្រាយបញ្ហាមីន/ស.ផ.ស. ដែលនៅសល់ត្រូវបានរៀបចំឡើង និងអនុម័ត | | | | ចាប់ផ្ដើម (២០១៣) | | | រៀបចំយុទ្ធសាស្ត្រជាតិដើម្បីដោះស្រាយបញ្ហាមីន/ស.ផ.ស. ដែលនៅសេសសល់ |
| | ផែនការដកថយរបស់អង្គការដោះមីនអន្តរជាតិត្រូវបានរៀបចំឡើងស្របនឹងយុទ្ធសាស្ត្រជាតិ ដើម្បីដោះស្រាយបញ្ហាមីន/ស.ផ.ស. ដែលនៅសេសសល់ និងផ្ដល់ជម្រើសការងារដល់បុគ្គលិករបស់អង្គការទាំងនោះ | | | | ចាប់ផ្ដើម (២០១៣) | | | រៀបចំផែនការដកថយរបស់អង្គការបោសសម្អាតមីនអន្តរជាតិ |
| ៣.២. រកឲ្យឃើញ និងដោះស្រាយចន្លោះខ្វះខាតផ្នែកសមត្ថភាព | ផែនការកសាងសមត្ថភាពត្រូវបានរៀបចំឡើងដោយបញ្ចូលតម្រូវការទាំងអស់ត្រឹម ឆ្នាំ២០១៥ | | | | | ចាប់ផ្ដើម | | រៀបចំផែនការអភិវឌ្ឍសមត្ថភាព |
| | ការអនុវត្ត: អត្រាភាគរយនៃលទ្ធផលសម្រេចបានធៀបនឹងផែនការ | % | | | | | | អនុវត្តផែនការអភិវឌ្ឍសមត្ថភាព |
| ៣.៣. ស្វានិរន្តរភាពសមត្ថភាពជាតិ | ការកៀរគរធនធាន: អត្រាភាគរយនៃធនធានដែលទទួលបាន ដើម្បីគាំទ្រផែនការអភិវឌ្ឍសមត្ថភាពធៀបនឹងធនធានដែលត្រូវការ | % | | | | | | ធានាការឆ្លើយតបសមស្របឲ្យបានជាប្រចាំ |
| | ការពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាពផែនការអភិវឌ្ឍសមត្ថភាព | អត្ថបទ | | | | ចាប់ផ្ដើម សាកល្បង (២០១៧) | | |

[១៩] នឹងចាប់ផ្ដើមពិនិត្យឡើងវិញបន្ទាប់ពីបញ្ចប់ការស្រាវជ្រាវទិន្នន័យមូលដ្ឋាននៅឆ្នាំ ២០១២

## គោលដៅទី៤: លើកកម្ពស់ស្ថិរភាព និងការរំសាយសញ្ញាវុធនៅក្នុងតំបន់ និងលើឆាកអន្តរជាតិ

| គោលដៅ | សូចនាករ | ឯកតា | ទិន្នន័យមូលដ្ឋាន | | | | | សកម្មភាព |
|---|---|---|---|---|---|---|---|---|
| | | | ២០០៩ | ២០១០ | ២០១២ | ២០១៥ | ២០១៩ | |
| ៤.១. គាំទ្រអនុសញ្ញា អ.ហ.ផ.ម. | អត្រាភាគរយនៃការសម្រេចបានតាមចំណុចដៅដែលមានចែងនៅក្នុងសំណើសុំពន្យារពេល | % | ០ | ១០ | ៣០ | ៥០ | ១០០ | ធ្វើរបាយការណ៍វឌ្ឍនភាពស្តីពីលទ្ធផលបោសសម្អាតមីន |
| | អត្រាភាគរយនៃការអនុវត្ត ផ.ជ.ស.ជ. តាមរបាយការណ៍របស់ ក.ស.អ.យ. | % | មិនទាន់មានទិន្នន័យ | កំពុងសិក្សា | នឹងមានទិន្នន័យ | ទិន្នន័យ | ទិន្នន័យ | ធ្វើរបាយការណ៍ស្តីពីការឧបត្ថម្ភគាំទ្រជនរងគ្រោះ |
| | ប្រព័ន្ធរបាយការណ៍ស្តីពីការអប់រំកាត់បន្ថយគ្រោះថ្នាក់ ត្រូវបានបង្កើតនៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានថ្នាក់ជាតិ | អត្ថបទ | មិនទាន់អនុវត្ត | សិក្សាពីប្រព័ន្ធសមាហរណកម្ម | សមាហរណកម្ម | នីត្តរភាព | នីត្តរភាព | ធ្វើរបាយការណ៍ស្តីពីបញ្ហានានាទាក់ទងនឹង អ.ហ.ផ.ម. |
| | របាយការណ៍ស្តីពីការរក្សាទុកគ្រាប់មីនសម្រាប់ការ ហ្វឹកហ្វឺនតាមរយៈយន្តការប្រព័ន្ធកត់ត្រាតាមដានជាប្រចាំ | អត្ថបទ | មាន | មាន | មាន | មាន | មាន | |
| | របាយការណ៍ស្តីពីការរក្សាទុកគ្រាប់មីនសម្រាប់ការ ហ្វឹកហ្វឺនតាមរយៈយន្តការប្រព័ន្ធកត់ត្រាតាមដានជាប្រចាំ | អត្ថបទ | សិក្សាពីលទ្ធភាព | រៀបចំ និងដឹកនាំកិច្ចប្រជុំលើកទី១១នៅចុងឆ្នាំ២០១១ | | | | ធ្វើម្ចាស់ផ្ទះកិច្ចប្រជុំលើកទី១១ នៃរដ្ឋភាគី អ.ហ.ផ.ម. |
| | ចំនួនអ្នកចូលរួមកិច្ចប្រជុំលើកទី១១ | នាក់ | | ៧០០នាក់ | | | | |
| ៤.២. គាំទ្រការចុះហត្ថលេខាលើពិធីសារ៥ ស្តីពី ស.ផ.ស.នៃអនុសញ្ញាសព្វាវុធធម្មតាមួយចំនួនចន្លោះខ្វះខាតផ្នែកសមត្ថភាព | កម្ពុជាផ្តល់សច្ចាប័នលើពិធីសារ ៥ ស្តីពី ស.ផ.ស. នៃអនុសញ្ញាសព្វាវុធធម្មតាមួយចំនួន | | | | ផ្តល់សច្ចាប័ន | | | គាំទ្រការចុះហត្ថលេខាលើពិធីសារ៥ ស្តីពី ស.ផ.ស. នៃអនុសញ្ញាសព្វាវុធធម្មតាមួយចំនួន |
| | ចំនួនការចូលរួមកិច្ចប្រជុំពិធីសារ៥ ស្តីពី ស.ផ.ស.នៃអនុសញ្ញាសព្វាវុធធម្មតាមួយចំនួន | ចំនួន | តាមការចាំបាច់ | តាមការចាំបាច់ | តាមការចាំបាច់ | តាមការចាំបាច់ | តាមការចាំបាច់ | ធ្វើបច្ចុប្បន្នភាពស្តីពីដំណើរការចុះហត្ថលេខា លើពិធីសារ៥ ស្តីពី ស.ផ.ស. នៃអនុសញ្ញាសព្វាវុធធម្មតាមួយចំនួន |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៤.៣. គាំទ្រការងារ បោះបង្គោលព្រំដែន | ចំនួនការចូលរួមកិច្ចប្រជុំជាមួយគណៈកម្មការព្រំដែនចម្រុះ | ចំនួន | តាមការអញ្ជើញ | តាមការអញ្ជើញ | តាមការអញ្ជើញ | តាមការអញ្ជើញ | តាមការអញ្ជើញ | ផ្តល់ព័ត៌មានពាក់ព័ន្ធតំបន់មានមីន/ស.ផ.ស. ជូនគណៈកម្មការព្រំដែនចម្រុះ |
| | ចំនួនសំណើសុំព័ត៌មានរបស់គណៈកម្មការព្រំដែនចម្រុះ ដែលបានឆ្លើយតប | % | ១០០ | ១០០ | ១០០ | ១០០ | ១០០ | |
| | គាំទ្រប្រតិបត្តិការដើម្បីបោសសម្អាតមីនតាមព្រំដែន | | គ្មានតួលេខ | តាមសេចក្តីត្រូវការ | តាមសេចក្តីត្រូវការ | តាមសេចក្តីត្រូវការ | តាមសេចក្តីត្រូវការ | ជួយប្រតិបត្តិការដោះមីនតាមព្រំដែន |
| ៤.៤. គាំទ្រការងារបោសសម្អាតមីនក្នុងក្របខ័ណ្ឌបេសកកម្មរក្សាសន្តិភាពអង្គការសហប្រជាជាតិ | ចំនួនកងដោះមីនរបស់មជ្ឈមណ្ឌលគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាពបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ដែលទទួលបានប័ណ្ណទទួលស្គាល់ពីអាជ្ញាធរមីនកម្ពុជា | កងអនុសេនាតូច | ១ | ៥ | ៩ | ១៤ | ២១ | រក្សាសមត្ថភាពអ្នកដោះមីនកម្ពុជាក្នុងកិច្ចការប្រតិបត្តិការរក្សាសន្តិភាពអង្គការសហប្រជាជាតិ |
| | ចំនួនអ្នកដោះមីនដែលបានបញ្ជូនឲ្យទៅចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ | នាក់ | ១៣៩ | ២៧០ | ២៧០ | ២៧០ | ២៧០ | ជួយគាំទ្រឲ្យមានការចូលរួមកាន់តែច្រើនឡើងរបស់កងយោធពលខេមរភូមិន្ទនៅក្នុងបេសកកម្មរក្សាសន្តិភាពអង្គការសហប្រជាជាតិ |
| ៤.៥. ផ្លាស់ប្តូរបទពិសោធន៍ក្នុងកម្រិតជាតិតំបន់និងអន្តរជាតិ | ចំនួនបទបង្ហាញដែលបានធ្វើតាមវេទិកានានា ទាំងថ្នាក់ជាតិ តំបន់ និង អន្តរជាតិ | ចំនួន | ២០ | ២០ | ២៥ | ២៥ | ៣០ | ចូលរួម និងចែករំលែកបទពិសោធន៍តាមរយៈសិក្ខាសាលាថ្នាក់ជាតិ តំបន់ និងអន្តរជាតិ |
| | ចំនួនទស្សនកិច្ចរបស់ដៃគូពាក់ព័ន្ធនឹងកម្មវិធីសកម្មភាពមីន(ក្នុងមួយឆ្នាំ) | ចំនួន | ២ | ១០ | ១៥ | ១៥ | ១៦ | ទទួលភ្ញៀវជាដៃគូពាក់ព័ន្ធក្នុងសកម្មភាពមីន ដើម្បីចែករំលែកបទពិសោធន៍ការងារ និងចំណេះដឹង និងបណ្តុះបណ្តាលជំនាញពាក់ព័ន្ធដែលមាន |

# ឧបសម្ព័ន្ធ ខ : តារាងវិភាជន៍ថវិកាពីឆ្នាំ ២០១០-២០១៩[១៦]

| ឆ្នាំ | លទ្ធផលនៃការបោសសម្អាតមីន ( ម២ ) | | តម្លៃ ( ដុល្លារ ) | | | |
|---|---|---|---|---|---|---|
| | លទ្ធផល ប្រចាំឆ្នាំ | លទ្ធផល សរុបបូកបន្ត | ថវិកាស្រាវជ្រាវទិន្នន័យ មូលដ្ឋាន ( ក ) | ថវិកាសម្រាប់បោស សម្អាតមីនប្រចាំឆ្នាំ ( ខ ) | ថវិកាសរុបប្រចាំឆ្នាំ ( ក + ខ ) | ថវិកាសរុបបូកបន្ត |
| 2009 | 38,627,620 | | 1,550,502 | 20,464,675 | 22,015,177 | |
| 2010 | 39,400,173 | 78,027,793 | 1,581,512 | 21,897,202 | 23,478,714 | 45,493,891 |
| 2011 | 40,188,176 | 118,215,969 | 1,613,142 | 23,430,006 | 25,043,148 | 70,537,039 |
| 2012 | 40,991,940 | 159,207,909 | 1,645,405 | 25,070,107 | 26,715,512 | 97,252,551 |
| 2013 | 41,811,778 | 201,019,687 | | 26,825,014 | 26,825,014 | 124,077,565 |
| 2014 | 42,648,014 | 243,667,701 | | 28,702,765 | 28,702,765 | 152,780,330 |
| 2015 | 43,500,974 | 287,168,676 | | 30,711,959 | 30,711,959 | 183,492,289 |
| 2016 | 44,370,994 | 331,539,670 | | 32,861,796 | 32,861,796 | 216,354,085 |
| 2017 | 45,258,414 | 376,798,083 | | 35,162,122 | 35,162,122 | 251,516,207 |
| 2018 | 46,163,582 | 422,961,665 | | 37,623,470 | 37,623,470 | 289,139,677 |
| 2019 | 47,086,854 | 470,048,519 | | 40,257,113 | 40,257,113 | 329,396,790 |

[១៦] តួលេខដកស្រង់ចេញពីឯកសារសុំពន្យារពេលបោសសម្អាតមីនសម្រាប់អាណត្តិ ១០ឆ្នាំ បន្តរបស់កម្ពុជា ដែលជាការប៉ាន់ប្រមាណដោយផ្អែកលើលទ្ធផលបោសសម្អាតមីននាពេលបច្ចុប្បន្នជាមួយនឹងទំហំថវិកាដែលធ្លាប់ទទួលបាន ដោយសន្មតិយកអត្រាកំណើន ២% សម្រាប់លទ្ធផលបោសសម្អាតមីនប្រចាំឆ្នាំ រហូតដល់ចុងឆ្នាំ ២០១៩ យើងនឹងអាចបោសសម្អាតមីនលើផ្ទៃដីជាង ៤៧០ គ.ម២។ យ៉ាងណាក្តី ដើម្បីសម្រេចបានតាមមាត្រាទី ៥ នៃ អ.ហ.ផ.ម. ក្នុងរយៈពេល ១០ឆ្នាំទៀត ២០១០-២០១៩ កម្ពុជាត្រូវការថវិកាសរុបប្រមាណ ៤៥៥ លានដុល្លារ ដើម្បីដោះផ្ទៃដីដែលសង្ស័យថាមានមីនទំហំ ១.០៩៧,៨ គ.ម២ តាមរយៈការស្រាវជ្រាវទិន្នន័យមូលដ្ឋាន និងការស្រាវជ្រាវបច្ចេកទេស និងការបោសសម្អាតមីនទាំងស្រុង ( full clearance )លើផ្ទៃដីទំហំ ៦៤៨,៨ គ.ម២។

**CAMBODIAN MINE ACTION AND VICTIM ASSISTANCE AUTHORITY (CMAA)**
New building, Corner of Streets 273 & 516, Toul Kork Village
Toul Sangke Quarter, Phnom Penh, Cambodia
Phone/Fax: +855 23 880 462/882 265
E-mail: cabinet@cmaa.gov.kh, info@cmaa.gov.kh
Website: www.cmaa.gov.kh